ឆ្នាំទី៥ លេខ ៥០ ខែ កុម្ភៈ ឆ្នាំ២០១៧

ព្រឹត្តិបត្រ

# កៅស៊ូធម្មជាតិ

# Natural Rubber Bulletin

ផ្សាយចេញពី អគ្គនាយកដ្ឋានកៅស៊ូ

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៦៧២២ ៥៩០



## នាយកបណ្ណាធិការ

- ឯកឧត្តម **ប៉ុល សុផា**

## គណៈកម្មាធិការបណ្ណាធិការ

- លោក **ឃុន កក្កដា** ប្រធាន
- លោក **ឃួន ផល្លា** អនុប្រធាន
- លោក **ហ៊ន សាផន** អនុប្រធាន
- លោក **គុយ ភក្តី** សមាជិកអចិន្ត្រៃយ៍
- លោក **ព្រៃ សុភាព** សមាជិក
- លោក **លួង សុខខេង** សមាជិក
- លោក **សុក សារុំ** សមាជិក
- លោក **អៀង ស៊ីថា** សមាជិក
- លោក **កែវ សំអុន** សមាជិក

## ការីកុំព្យូទ័រ

- លោក **យឹម ដារ៉ា**
- កញ្ញា **ស៊ឹម មុំ**
- លោក **ជុំ មៅ**

## ការីទំនាក់ទំនងនិងបោះពុម្ព

- លោក **គុយ ភក្តី**
- E-mail phokpheakdey@yahoo.com
- Tel: ០១៦ ២៩៣ ៤២៣

## Editor-in-chief

- H.E. Pol Shopha

## Editorial Board

- Mr. Khun Kakada Director
- Mr. Khuon Phalla Vice Director
- Mr. Horn Saphan Vice Director
- Mr. Kuy Pheakdey Permanent Member
- Mr. Prey Sopheap Member
- Mr. Loung Sokheng Member
- Mr. Sok Sarom Member
- Mr. Ieng Sitha Member
- Mr. Keo Somonn Member

## Computer Operator

- Mr. Yim Dara
- Miss. Sim Mom
- Mr. Chum Mouv

## Contact & Publication

- Mr. Kuy Pheakdey
- E-mail: phokpheakdey@yahoo.com
- Tel: 016 293 423

| មាតិកា | ទំព័រ |
| --- | --- |
| ❖ បទវិចារណកថា | ១ |
| **ព័ត៌មានក្នុងប្រទេស** | |
| ❖ វេទិកាស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២ |
| ❖ កិច្ចប្រជុំបូកសរុបលទ្ធផលការងារអគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ | ៤ |
| ❖ កិច្ចប្រជុំស្តីពី «គម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា» | ៩ |
| **ព័ត៌មានអន្តរជាតិ** | |
| ❖ របាយការណ៍ស្តីពី និន្នាការ & ស្ថិតិកៅស៊ូធម្មជាតិរបស់សមាគម ANRPC | ១៤ |
| ❖ អ្នកវិទ្យាសាស្ត្រសាកលវិទ្យាល័យ Minnesota បង្កើតនូវកៅស៊ូសំយោគធម្មជាតិ | ១៩ |
| **ទំព័រស្រាវជ្រាវ** | |
| ❖ ចលនការរបស់សារធាតុគីមីដែលប្រើប្រាស់ក្នុងការកែច្នៃជ័រកៅស៊ូធម្មជាតិ ( Latex) | ២២ |
| **តម្លៃនិងស្ថិតិកៅស៊ូធម្មជាតិ** | |
| ❖ តារាងទី១៖ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅតាមបណ្តាស្រុកប្រចាំសប្តាហ៍ ខែកុម្ភៈ ឆ្នាំ២០១៧ | ២៥ |
| ❖ តារាងទី២៖ តម្លៃកៅស៊ូនៅទីផ្សារប្រទេសថៃ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ | ២៦ |
| ❖ តារាងទី៣៖ តម្លៃកៅស៊ូស្តង់ដាម៉ាឡេស៊ី SMR/FOB ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ | ២៧ |
| ❖ តារាងទី៤៖ តម្លៃកៅស៊ូធម្មជាតិចេញដោយ Association of Natural Rubber Producing Countries ប្រចាំខែមករា ឆ្នាំ២០១៧ | ២៨ |
| ❖ តារាងទី៥៖ តម្លៃកៅស៊ូធម្មជាតិប្រចាំខែជាមធ្យមលើទីផ្សារសំខាន់ៗ | ២៩ |
| ❖ តារាងទី៦៖ ការនាំចេញកៅស៊ូធម្មជាតិរបស់ប្រទេសជាសមាជិកសមាគម ANRPC | ២៩ |
| ❖ តារាងទី៧៖ តម្លៃកៅស៊ូសន្លឹកលេខ៣ ( RSS3 ) នៅលើទីផ្សារហ៊ុន TOCOM | ៣២ |
| ❖ តារាងទី៨៖ តម្លៃកៅស៊ូសន្លឹកលេខ៣ ( RSS3 ) នៅលើទីផ្សារហ៊ុនសៀងហៃ | ៣៣ |
| **ចំណេះដឹងទូទៅ** | |
| ❖ ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ | ៣៤ |
| **ក្រាហ្វិក** | |
| ❖ ក្រាហ្វិកទី១៖ តម្លៃកៅស៊ូប្រភេទ SMR 20 ធៀបនឹងតម្លៃប្រេងឆៅរបស់ក្រុមហ៊ុន Brent | ៣០ |
| ❖ ក្រាហ្វិកទី២៖ និន្នាការតម្លៃកៅស៊ូនៅពេលអនាគត RSS3 នៅទីផ្សារ TOCOM និង លុយយ៉េន ប្រទេសជប៉ុន | ៣១ |

# បទវិចារណកថា

*ប្រិយមិត្តទាំងអស់ជាទីមេត្រី!*

យោងតាមបច្ចុប្បន្នភាពព័ត៌មានថ្មីៗបំផុត ដែលមានប្រភពពីប្រទេសជាសមាជិកនៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) បានរំពឹងទុកថា ផលិតផលកៅស៊ូធម្មជាតិសរុបនៅក្នុងសមាគមនេះនឹងកើនឡើងប្រមាណ ៤,២% នៅក្នុងឆ្នាំ២០១៧ ស្របពេលដែលការផ្គត់ផ្គង់មានកំណើនគួរឲ្យកត់សម្គាល់ផងដែរនៅតាមបណ្តាប្រទេសជាសមាជិក លើកលែងតែនៅក្នុងប្រទេសឥណ្ឌូណេស៊ីដែលនឹងមានការថយចុះបន្តិចបន្តួច។

ទោះជាយ៉ាងនេះក្តី នៅក្នុងអំឡុងពេលពីរខែដំបូងនៃដើមឆ្នាំ២០១៧ ផលិតផលកៅស៊ូធម្មជាតិបានធ្លាក់ចុះប្រមាណ ២,២% ដោយសារតែមូលហេតុសំខាន់ពីរគឺៈ (១) គ្រោះទឹកជំនន់នៅភាគខាងត្បូងប្រទេសថៃដែលត្រូវបានគេចាត់ទុកថាជាចានត្រងជ័រកៅស៊ូធម្មជាតិរបស់ពិភពលោក និង (២) ការឈានចូលរដូវជ្រុះស្លឹកកៅស៊ូឆាប់រហ័សជាងធម្មតា ដែលបណ្តាលឲ្យមានការសម្រាកចៀរជ័រជាទូទៅ។

ការធ្លាក់ចុះការផ្គត់ផ្គង់កៅស៊ូធម្មជាតិនៅក្នុងអំឡុងពេលពីរខែដំបូងនៃដើមឆ្នាំ២០១៧នេះ បានកើតឡើងស្របពេលដែលបរិមាណតម្រូវការមានកំណើនឡើងប្រមាណ ៣,៣% នៅក្នុងសមាគម ANRPC។ អតុល្យភាពរវាងការផ្គត់ផ្គង់និងតម្រូវការអាចនឹងនៅតែបន្តកើតឡើងទៀតចាប់ពីខែមីនារហូតដល់ខែឧសភា ឆ្នាំ២០១៧។

ភាពអនុគ្រោះជាសារវន្តនៃកត្តាផ្គត់ផ្គង់និងតម្រូវការ រួមផ្សំនឹងកត្តាអនុគ្រោះផ្សេងៗទៀត នឹងនៅតែបន្តគាំទ្រតម្លៃនៅលើទីផ្សារ។ តម្លៃកៅស៊ូធម្មជាតិអាចនឹងបន្តរំកិលឡើងទៀត ដែលជាការឆ្លើយតបទៅនឹងដំណើរវិវឌ្ឍន៍នៃប្រេងឆៅ បម្រែបម្រួលរូបិយប័ណ្ណ និងនិន្នាការលំហូរមូលនិធិ។

ក្រុមការងារព្រឹត្តិបត្រកៅស៊ូធម្មជាតិនៃអគ្គនាយកដ្ឋានកៅស៊ូ នឹងនៅតែបន្តយកចិត្តទុកដាក់តាមដានពីគ្រប់មជ្ឈដ្ឋាននិងប្រភពព័ត៌មាននានា ដើម្បីផ្តល់ជូនដល់មិត្តអ្នកអាននូវខ្លឹមសារនិងរូបភាពកាន់តែច្បាស់ថែមទៀត អំពីស្ថានភាពអភិវឌ្ឍនាពេលបច្ចុប្បន្ន និន្នាការទីផ្សារ និងទស្សនវិស័យសម្រាប់រយៈពេលខ្លី មធ្យម និងវែងនៃឧស្សាហកម្មកៅស៊ូធម្មជាតិ ទាំងក្នុងក្របខណ្ឌជាតិ តំបន់ និងពិភពលោក។

# ព័ត៌មានក្នុងប្រទេស

## វេទិកាស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំវេទិកាស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រយៈពេលមួយថ្ងៃពេញ ក្រោមអធិបតីភាព ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងក្រសួងស្ថាប័នពាក់ពន្ធ័ អាជ្ញាធររាជធានីខេត្ត ឯកឧត្តម អស់លោក លោកស្រី ជាតំណាងអង្គភាពជំនាញ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ ភ្ញៀវជាតិនិងអន្តរជាតិ តំណាងពីវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល ហើយនិងតំណាងសហគមន៍កសិកម្ម ព្រៃឈើ និងជលផលយ៉ាងច្រើនកុះករសរុបប្រមាណជាង ៥០០នាក់។ សូមបញ្ជាក់ជូនជ្រាបថា ការរៀបចំវេទិកានេះ គឺជាការអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ប្រកបដោយកិត្តិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងក្នុងវេទិកាស្តីពី «ការការពារនិងអភិរក្សធនធានធម្មជាតិ» នៅថ្ងៃទី២២ សីហា ២០១៦ កន្លងមក។




*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងឱកាសបើកវេទិកាស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ*



*ទិដ្ឋភាពនៃវេទិកា*

វេទិកានេះត្រូវបានរៀបចំឡើងក្នុងស្មារតីស្ថាបនា ដើម្បីប្រមូលធាតុចូលឲ្យបានគ្រប់ជ្រុងជ្រោយ សំដៅរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា ក្នុងគោលបំណងផ្តល់ឱកាសដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ចូលរួមគំនិតយោបល់លើ៖

(១)-ស្វែងយល់អំពីការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំងបញ្ហាប្រឈមសំខាន់ៗ និងលើកសំណូមពរនានាពាក់ព័ន្ធនឹងការលើកកម្ពស់ផលិតកម្មកសិកម្មការគ្រប់គ្រងកសិផល និងទីផ្សារ

(២)-ពិភាក្សាចែករំលែកបទពិសោធន៍ មេរៀន ព័ត៌មាន និងចំណេះដឹងអំពីការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(៣)-រិះរកនិងកំណត់ដំណោះស្រាយលើបញ្ហាប្រឈមសំខាន់ៗ និងសំណូមពរនានា ព្រមទាំងភារកិច្ចការរួមចំណែក ឬការទទួលខុសត្រូវរបស់ភាគី និងអ្នកពាក់ព័ន្ធទាំងអស់។

សន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦-២០១៧ នាពេលឆាប់ៗខាងមុខនេះ ក៏នឹងយកលទ្ធផលនៃវេទិកានេះ ទៅពិនិត្យ និងពិភាក្សាបន្ថែមទៀត ដើម្បីដាក់ចេញដំណោះស្រាយ និងវិធានការអនុវត្តបន្ត។

អង្គវេទិកាបន្តពិភាក្សាលើបញ្ហានានា និងដាក់ចេញនូវវិធានការ និងដំណោះស្រាយ។ ទន្ទឹមនឹងនោះ ពាក់ព័ន្ធទៅនឹងបញ្ហាថ្លៃដើមខ្ពស់ក្នុងហវិស័យកៅស៊ូ តំណាងប្រតិបត្តិករចំនួន ២រូប បានសំណូមពរសំណើសុំបញ្ចុះអាករនាំចេញលើមុខទំនិញកៅស៊ូកែច្នៃ ដើម្បីឲ្យមានការប្រកួតប្រជែង។ អង្គវេទិកាបានទទួលយកនូវសំណើនេះដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

ជារួម វេទិកាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រព្រឹត្តិទៅដោយមានការចូលរួមមតិ យោបល់យ៉ាងផុលផុសត្រង់ទៅត្រង់មកប្រកបដោយភាពទទួលខុសត្រូវខ្ពស់ និងស្និទ្ធស្នាល ហើយទទួលបានលទ្ធផលផ្លែផ្កាតាមការរំពឹងទុក។ តួអង្គពាក់ព័ន្ធបានស្នើសុំឲ្យមានការរៀបចំវេទិកានេះឲ្យបានមួយឆ្នាំម្តង ដើម្បីយល់ពីស្វែងគ្នានិងរួមគ្នាកំណត់បញ្ហាប្រឈម ដំណោះស្រាយ និងវិធានការសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនាពេលអនាគត។



*ទិដ្ឋភាពនៃវេទិកា*



*លោកឧកញ៉ា **ម៉ក់ គីមហុង** ប្រធានសមាគមអភិវឌ្ឍកៅស៊ូកម្ពុជា បានលើកសំណូមពរ*

# កិច្ចប្រជុំបូកសរុបលទ្ធផលការងារអគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧

កាលពីថ្ងៃទី២៧-២៨ ខែកុម្ភៈ ឆ្នាំ២០១៧ អគ្គនាយកដ្ឋានកៅស៊ូបានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧។ កិច្ចប្រជុំនេះមានគោលបំណងពីរគឺៈ (១) ផ្តល់ជាវេទិកាជួបជុំរវាងថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់នាយកដ្ឋាន និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យកៅស៊ូតាមបណ្តាខេត្ត សមាគមកៅស៊ូ និងវិស័យឯកជន (ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម) ដើម្បីពិភាក្សាលើលទ្ធផលការងារវិស័យកៅស៊ូសម្រេចបានក្នុងឆ្នាំ២០១៦ ពិនិត្យលើបញ្ហាប្រឈម និងរកដំណោះស្រាយសម្រាប់ការអនុវត្តបន្តនាពេលខាងមុខ និង (២) កំណត់ទិសដៅការងារនិងភារកិច្ចដែលត្រូវអនុវត្តបន្តតាមកម្មវិធី ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរាជរដ្ឋាភិបាលបានអនុម័តសម្រេចផ្តល់ ថវិកា សម្ភារៈ និងមធ្យោបាយចាំបាច់នានាសម្រាប់បំពេញការងារនៅក្នុងឆ្នាំ២០១៧ខាងមុខ។

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ពិធីបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានកៅស៊ូ បានចាប់ផ្តើមឡើងដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **លី ផល្លា** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាគណៈអធិបតី ព្រមទាំង ឯកឧត្តម លោក លោកស្រីជាថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក លោកស្រី នាងកញ្ញាជាមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មន្ទីរកសិកម្មខេត្ត និងវិស័យឯកជនសរុបមានចំនួន១៥៥នាក់។





*ឯកឧត្តម **លី ផល្លា** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញជាគណៈអធិបតី ក្នុងពិធីបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារអគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧*

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ បានថ្លែងសុន្ទរកថាស្វាគមន៍ដល់គណៈអធិបតីនិងអង្គពិធីស្តីអំពី ស្ថានភាពនៃការអភិវឌ្ឍកៅស៊ូធម្មជាតិនៅទូទាំងប្រទេសក្នុងឆ្នាំ២០១៦ ដោយផ្តោតលើតម្លៃកៅស៊ូ និន្នាការទីផ្សារកៅស៊ូអន្តរជាតិ

សកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូលើឆាកអន្តរជាតិ និងបញ្ហាប្រឈមមួយចំនួន ដែលអគ្គនាយកដ្ឋានកៅស៊ូ ជួបប្រទះនាពេលកន្លងមក។



*ឯកឧត្តម **ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ បានថ្លែងសុន្ទរកថាស្វាគមន៍ ដល់គណៈអធិបតី និងអង្គពិធី*

ជាកិច្ចបន្ត ឯកឧត្តម **លី ផល្លា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាង ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានថ្លែងសុន្ទរកថាបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានកៅស៊ូ ដោយបានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ ដែលបានខិតខំយកអស់ស្មារតីនឹងកម្លាំងកាយចិត្តក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធ្វើឱ្យអនុវិស័យកៅស៊ូមានការវិវត្តឈានទ្បើង។ ឯកឧត្តមរដ្ឋលេខាធិការ ក៏បានរំលឹកជូនអង្គប្រជុំផងដែរនូវសារៈសំខាន់របស់ដំណាំកៅស៊ូ ដែលជាដំណាំយុទ្ធសាស្ត្រមួយប្រភេទផ្តល់នូវពហុប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមជាតិ និងដល់បរិស្ថាន ជាពិសេស ការរួមចំណែកដល់ប្រាក់ចំណូលសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារកសិករ រួមចំណែក កាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារ និងមុខរបរដែលមានស្ថេរភាពជូនប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ជនបទ កាត់បន្ថយការធ្វើចំណាកស្រុក និងការផ្តល់ឈើសម្រាប់ប្រើប្រាស់ផលិតគ្រឿងសង្ហារឹម ជាឈើឥន្ធនៈ កាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះដី និងជាគម្របបៃតង ក្នុងការថែរក្សាលំនឹងបរិស្ថាន ដោយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមដ៏សំខាន់របស់ពិភពលោកក្នុងពេលបច្ចុប្បន្ន។ ក្នុងឱកាសនោះ ឯកឧត្តមគណៈអធិបតី បានលើកឡើងនូវប្រធានបទសំខាន់ ២ សម្រាប់អង្គសន្និបាតធ្វើការពិភាក្សា៖

១.បញ្ហាដែលអនុវិស័យកៅស៊ូបាន និងកំពុងប្រឈមចំពោះមុខ

២. យន្តការដំណោះស្រាយចំពោះបញ្ហាប្រឈមដែលអនុវិស័យកៅស៊ូកំពុងជួបប្រទះនិងមិនទាន់បានអនុវត្តដូចជា សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ការបង្កើតស្នាក់ការប្រមូលទិញទឹកជ័រនិងជ័រស្ងួត ការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រ ការបង្កើតសហគមន៍កៅស៊ូគ្រួសារ។

នាថ្ងៃដដែល អង្គប្រជុំបានធ្វើបទបង្ហាញនិងពិភាក្សាតាមប្រធានបទដែលបានគ្រោងទុក ដោយមានការលើកឡើងពីតំណាងសមាគមកៅស៊ូ វិស័យឯកជន ចម្ការកៅស៊ូកសិឧស្សាហកម្ម មន្ទីរកសិកម្មខេត្ត។ ជាលទ្ធផល អង្គប្រជុំប្រមូលបាននូវមតិយោបល់ សំណូមពរ និងបញ្ហាមួយចំនួនរួមមាន៖

✓ សុំបង្កើនការប្រមូលផ្តុំទិន្នន័យស្ថិតិកៅស៊ូឱ្យបានកាន់តែប្រសើរជាងនេះ

✓ ជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ដោយស្នើសុំឱ្យមានការពិគ្រោះយោបល់ជាមួយវិស័យឯកជន

✓ ស្នើសុំជំរុញឱ្យមានការអនុវត្តគម្រោងកៅស៊ូគ្រួសារ ព្រោះប្រជាជនកំពុងមានការចាប់អារម្មណ៍

✓ ជំរុញការគ្រប់គ្រង និងប្រមូលរបាយការណ៍ពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច

✓ បង្កើនការចុះពិនិត្យស្ថានភាពនិងណែនាំបច្ចេកទេសដល់ក្រុមហ៊ុនចម្ការកៅស៊ូតាមបណ្តាខេត្ត

✓ ជំរុញវិធានការក្នុងការទប់ស្កាត់ការហូរចេញនូវជ័រកៅស៊ូ មិនទាន់កែច្នៃទៅបរទេស

✓ អំពាវនាវឱ្យក្រុមហ៊ុនចម្ការកៅស៊ូទាំងអស់ចូលជាសមាជិកសមាគមអភិវឌ្ឍកៅស៊ូកម្ពុជា

✓ ជួយរកដំណោះស្រាយការខ្វះខាតធនធានមនុស្សសម្ភារៈ និងមធ្យោបាយ ធ្វើការរបស់ការិយាល័យកៅស៊ូនៅតាមមន្ទីរកសិកម្មរាជធានីខេត្ត និង

✓ ការលំបាកក្នុងការអនុវត្តអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្តីពី ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ពិធីបិទកិច្ចប្រជុំបូកសរុបការងារអគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ បានប្រព្រឹត្តធ្វើឡើងក្រោមអធិបតីភាព ឯកឧត្តម **លី ផល្លា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង លោក លោកស្រីជាថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួង។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ បានធ្វើរបាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំបូកសរុបលទ្ធផលការងារកៅស៊ូឆ្នាំ២០១៦ ដោយបានជម្រាបជូនថា ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤៣៣ពាន់ហិកតា បើធៀបនឹងឆ្នាំ២០១៥ មាន ៣៨៩ពាន់ហិកតា កើនឡើងជិត ៤៤ពាន់ហិកតា ក្នុងនោះផ្ទៃដីចម្ការ កៅស៊ូកសិឧស្សាហកម្មមានចំនួនប្រមាណ ២៧៨ពាន់ហិកតា ស្មើនឹង ៦៤% និងផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន ១៥៥ពាន់ហិកតា ស្មើនឹង ៣៦% នៃផ្ទៃដីសរុប។ ផ្ទៃដីកៅស៊ូចៀរជ័រមានចំនួន ១២៧ពាន់ហិកតា ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០១៥ ដែលមាន ១១១ពាន់ហិកតា គឺកើនឡើង ១៦ពាន់ហិកតា ស្មើនឹង ១៤%។ ផលិតផលកៅស៊ូស្ងួតសម្រេចបានចំនួនជាង ១៤៥ពាន់តោន ធៀបនឹងឆ្នាំ២០១៥ ដែលមានចំនួនប្រមាណ ១២៧ពាន់តោន គឺកើនឡើង ១៤%។ ការនាំចេញកៅស៊ូក្នុងឆ្នាំ ២០១៦ សម្រេចបានចំនួនប្រមាណជាង ១៤៥ពាន់តោន បើធៀបនឹងឆ្នាំ២០១៥ ដែលមានចំនួន ១២៨ពាន់តោន គឺកើនឡើង ១៣,២៨% តែចំណូលកើនឡើងតែបន្តិចប៉ុណ្ណោះ ដោយសារស្ថានភាពតម្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិ បានធ្លាក់ចុះទាបយ៉ាងខ្លាំងក្នុងឆ្នាំ២០១៥

និងបន្តធ្លាក់ចុះដល់ត្រីមាសទី៣ ឆ្នាំ២០១៦ ដែលមិនធ្លាប់មានក្នុងរយៈពេល៩ឆ្នាំកន្លងមក ជាពិសេសនៅដើមឆ្នាំ២០១៦ ដែលមានតម្លៃតែ ១.១៥០ដុល្លារ/តោនប៉ុណ្ណោះ។ តម្លៃកៅស៊ូមធ្យមនៅឆ្នាំ២០១៦ គឺ ១ ២៩០ ដុល្លារ/តោន ធៀបទៅនឹងតម្លៃមធ្យម ១ ២០៣ដុល្លារ/តោន នៅក្នុងឆ្នាំ២០១៥ គឺកើនឡើង ៨៧ដុល្លារ/តោន ស្មើនឹង ៧,២៣%។ ការងារសំខាន់ៗជាច្រើនទៀតត្រូវបានលម្អិតក្នុងសៀវភៅរបាយការណ៍បូកសរុបការងារអគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ ដូចជា ការនាំចេញកៅស៊ូនាពេលអនាគត, ការងារស្រាវជ្រាវបច្ចេកទេស, ការងារបន្តជំរុញចងក្រង និងពង្រឹងសហគមន៍កសិករកៅស៊ូគ្រួសារ, ជំរុញអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាឱ្យមានវឌ្ឍនភាព, ការងារបន្តកៀរគរនិងទាក់ទាញដៃអភិវឌ្ឍន៍ និងបន្តការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកវិទ្យាដំណាំកៅស៊ូ។

ឯកឧត្តម **លី ផល្លា** តំណាងឲ្យ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃសន្និបាត និងបានដាក់ចេញនូវអនុសាសន៍ដើម្បីឲ្យអគ្គនាយកដ្ឋានកៅស៊ូយកទៅអនុវត្តន៍បន្តមានដូចខាងក្រោម៖

(១)ត្រូវធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជា ឱ្យសមស្របនឹងស្ថានភាពជាក់ស្តែងនិងទៅអនាគត។ ដូច្នេះ ចាំបាច់ត្រូវប្រមូលធាតុចូលឱ្យគ្រប់គ្រាន់និងត្រឹមត្រូវសម្រាប់រៀបចំធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រនេះ ដែលតម្រូវឱ្យអគ្គនាយកដ្ឋានកៅស៊ូ ត្រូវចុះពិនិត្យនិងណែនាំទៅដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចឱ្យរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការគ្រប់គ្រងនិងការអនុវត្តប្រចាំខែប្រចាំឆ្នាំ រួមនឹងគម្រោងផែនការដាំដុះនិងផែនការអាជីវកម្មប្រចាំឆ្នាំ រួចផ្ញើមកអគ្គនាយកដ្ឋានកៅស៊ូជាចាំបាច់

(២)-ត្រូវយកចិត្តទុកដាក់ចំពោះការនាំចេញកៅស៊ូនាពេលអនាគត។ យើងដឹងថាក្នុងឆ្នាំ២០១៦នេះយើងបាននាំចេញកៅស៊ូជាង ១៤ម៉ឺនតោន ហើយផ្ទៃដីកៅស៊ូបានកើនឡើងដល់ជាង៤៣ម៉ឺនហិកតា។ ដូច្នេះអគ្គនាយកដ្ឋានកៅស៊ូត្រូវគិតគូរជាចម្បងទៅលើ៖ (១) ខិតខំរកទីផ្សារថ្មីថែមទៀត ដោយធានាឱ្យទីផ្សារកៅស៊ូអន្តរជាតិមានការទទួលស្គាល់ផលិតផលកៅស៊ូកម្ពុជាជាផលិតផលមានគុណភាពតាមស្តង់ដារត្រឹមត្រូវ។ ដូចនេះការនាំចេញផលិតផលកៅស៊ូទៅបរទេស ចាំបាច់ត្រូវតែមានវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ និង (២)ត្រូវពិនិត្យឡើងវិញអំពីយន្តការគ្រប់គ្រងមួយឱ្យបានច្បាស់លាស់ ចំពោះចម្ការកៅស៊ូកសិឧស្សាហកម្ម និងចម្ការកៅស៊ូគ្រួសារ រួមទាំងរោងចក្រនិងសិប្បកម្មកែច្នៃកៅស៊ូបឋម។ ទន្ទឹមនឹងនេះ ក៏ត្រូវពិភាក្សាគិតគូរទៅលើកង្វល់និងសំណូមពរទាំងឡាយដែលបានលើកឡើងពាក់ព័ន្ធវិស័យកៅស៊ូក្នុងអង្គវេទិកាកាលពីថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៧ កន្លងមកនេះ

(៣)-ត្រូវសិក្សាបន្ថែម៖ (១)ការងារស្រាវជ្រាវបច្ចេកទេស ដូចជា ការដាំដុះ ការថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចម្រៀង ការយកផល និងការកែច្នៃ (២)ការពង្រីកទីតាំងស្ថានីយនិងមន្ទីរពិសោធន៍ និងបង្កើនសមត្ថភាពស្រាវជ្រាវ ផ្សព្វផ្សាយ បង្ហាញ និងផ្ទេរបច្ចេកវិទ្យា (៣)ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រីកនិងរក្សាទុកប្រភពផ្តល់រុក្ខសម្ភារដើមកៅស៊ូសម្រាប់ការអភិវឌ្ឍចម្ការកៅស៊ូនាពេលអនាគត ពិសេសច្បារពូជដែលបានធ្វើ DNA រួចហើយ។ ក្រៅពីការងារបច្ចេកទេស គឺនៅមានការងារគ្រប់គ្រងនិងការងារអភិវឌ្ឍន៍ផងដែរ។ ដូចនេះ ត្រូវខិតខំប្រឹងប្រែងរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ដើម្បីប្រើប្រាស់ក្នុងតំណាក់កាលចាំបាច់ចំពោះមុខនេះ

(៤)-ត្រូវបន្តជំរុញចងក្រងនិងពង្រឹងសហគមន៍កសិករកៅស៊ូគ្រួសារ ដើម្បីបង្កើតកាលានុវត្តភាពក្នុងការការពារផលប្រយោជន៍របស់កសិករទាំងការដាំដុះ ការយកផល ការកែច្នៃ និងទាំងអំណាចនៃការចរចាថ្លៃពេលលក់ផលិតផលរបស់គាត់។ ប្រសិនបើសហគមន៍នេះកើតបានច្រើននោះ កសិករកៅស៊ូគ្រួសារនឹងមានលទ្ធភាពស្វែងរកប្រភពទុន អាចកសាងមណ្ឌល ឬមជ្ឈមណ្ឌលកែច្នៃផលិតផលកៅស៊ូរួមដោយខ្លួនឯងដែលនេះជាឱកាសឱ្យកសិករអាចដើរដល់ទីផ្សារដោយខ្លួនឯងបាន ជៀសផុតពីការគៀបសង្កត់ថ្លៃពីអ្នកប្រមូលទិញផងដែរ

(៥)-ជំរុញអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាឱ្យមានវឌ្ឍនភាពប្រកបដោយក្តីសង្ឃឹមខ្លាំងថែមទៀត តាមរយៈកត្តាឆន្ទៈនិងកត្តាសាមគ្គីភាពផ្ទៃក្នុងជាធ្លុងមួយប្រកបដោយការយកចិត្តទុកដាក់ខ្ពស់និងមហិច្ឆិតា។ ទន្ទឹមនេះ ក៏ត្រូវចូលរួមពង្រឹងសមត្ថភាពមន្ត្រីនៅការិយាល័យកៅស៊ូនៅតាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តដែលមានសក្តានុពលខាងកៅស៊ូ ដើម្បីជួយពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ

(៦)-ត្រូវបន្តកៀរគរនិងទាក់ទាញរកប្រភពហិរញ្ញប្បទាន ឬបច្ចេកវិទ្យាពីដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតដើម្បីអនុវត្តឱ្យសម្រេចគោលដៅសូចនាករនៃផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូកម្ពុជាឱ្យទទួលបានជោគជ័យ។ ទន្ទឹមនឹងនេះ ក៏មិនត្រូវមើលរំលងអំពីការខិតខំអនុវត្តធ្វើការប្រមូលចំណូលបានពីការជួលទីតាំងដី ទីតាំងចម្ការកៅស៊ូ និងអចលនទ្រព្យផ្សេងទៀតក្រោមសមត្ថកិច្ចរបស់ខ្លួនឱ្យបានសម្រេចតាមគោលដៅដែលគ្រោងទុក

(៧)-បន្តការបណ្តុះបណ្តាលនិងផ្សព្វផ្សាយបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករដាំកៅស៊ូឱ្យបានច្រើនថែមទៀតអំពីការដាំដុះ ការថែទាំ ការដាំដំណាំចន្លោះរងកៅស៊ូ ការយកផល ការទុកដាក់ផលិតផលជ័រកៅស៊ូ ការកែច្នៃកៅស៊ូសន្លឹក ព្រមទាំង បន្តបង្កើនការបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករឱ្យបាន

ច្រើនថែមទៀត ស្របតាមសន្ទុះរីកចម្រើននៃផ្ទៃដីត្រូវប្រមូលផល។

ចុងបញ្ចប់នៃកម្មវិធីឯកឧត្តម **លី ផល្លា** បានបំពាក់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានកៅស៊ូ ដែលមានស្នាដៃល្អក្នុងការបម្រើការងារជូនជាតិមាតុភូមិនាពេលកន្លងមក។










## កិច្ចប្រជុំស្ដីពី «គម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា»

កាលពីថ្ងៃទី៧ កុម្ភៈ ឆ្នាំ២០១៧ នៅអគ្គនាយកដ្ឋានកៅស៊ូមានកិច្ចប្រជុំមួយស្ដីអំពី «ការធ្វើបទបង្ហាញលើសេចក្ដីព្រាងរបាយការណ៍នៃការចុះសិក្សាលទ្ធភាពអាចធ្វើបានដំណាក់កាលទី២ របស់ក្រុមហ៊ុន GLG Consultant លើគម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ ដោយមានវត្តមានចូលរួមពី ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD), តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, តំណាងធនាគារអភិវឌ្ឍន៍ជនបទ, តំណាងអង្គការ WWF, ថ្នាក់ដឹកនាំ ប្រធាន អនុប្រធាននាយកដ្ឋាន និងមន្ត្រីក្រោមឱវាទអគ្គនាយកដ្ឋានកៅស៊ូ។



*ឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុក ជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ បានអញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំ*

គោលបំណងនៃអង្គប្រជុំគឺ៖ ១)ស្តាប់ការធ្វើបទបង្ហាញលើរបាយការណ៍ចុះសិក្សាលទ្ធភាពដែលអាចធ្វើបាននៃគម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជារបស់ក្រុមហ៊ុន GLG Consultant និង ២)ពិភាក្សាលើសេចក្តីព្រាងរបាយការណ៍នេះ មុននឹងចេញរបាយការណ៍បញ្ចប់។ គួរបញ្ជាក់ផងដែរថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាពជាគោលការណ៍ក្នុងការអនុញ្ញាតឲ្យប្រើប្រាស់ថវិកានៅក្នុងមូលនិធិកោសល្យវិច្ឆ័យនិងការពង្រឹងសមត្ថភាព (FERC:Fonds d'Expertise et de Renforcement des Capacités) ដើម្បីធ្វើការសិក្សាអំពីលទ្ធភាពអាចធ្វើបានចំនួន ២លើក៖

❖ **ការចុះសិក្សាជំហានទី១៖** បានបញ្ចប់ចុះសិក្សាលទ្ធភាពអាចធ្វើបានបឋម (Pre-feasibility Study) នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤។ លទ្ធផលនៃការចុះសិក្សាបានលើកគម្រោងផែនការដាំកៅស៊ូជាលក្ខណៈគ្រួសារសម្រាប់រយៈពេល៥ឆ្នាំ សរុបផ្ទៃដីមានចំនួន១០ ៣០០ហិកតា

❖ **ការចុះសិក្សាជំហានទី២៖** បានចុះហត្ថលេខាលើកិច្ចសន្យារវាងអគ្គនាយកដ្ឋានកៅស៊ូ និងក្រុមហ៊ុន GLG Consultant នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៦ និងបានចុះសិក្សាចាប់ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦។ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ ការប្រជុំធ្វើបទបង្ហាញពីលទ្ធផលនៃការចុះសិក្សានេះបានប្រព្រឹត្តទៅនៅអគ្គនាយកដ្ឋានកៅស៊ូ។

ក្រោយពីបានសំដែងកិច្ចស្វាគមន៍ និងថ្លែងអំណរគុណចំពោះវត្តមានរបស់សមាជិកអង្គប្រជុំរួចមក ក្រុមហ៊ុន GLG Consultant បានធ្វើបទបង្ហាញលើសេចក្តីព្រាងរបាយការណ៍មានដូចខាងក្រោម៖

❖ ការចុះសិក្សានេះ ចាប់ផ្តើមពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ លើទិដ្ឋភាពបច្ចេកទេស សេដ្ឋកិច្ច ហិរញ្ញវត្ថុ បរិស្ថាន និងសង្គម លើខេត្តគោលដៅចំនួន ០២ គឺ ខេត្តរតនគិរីនិងខេត្តបាត់ដំបង។ ដោយឡែកចំពោះខេត្តកំពង់ចាមដែលជាខេត្តបានជ្រើសរើសក្នុងកំឡុងចុះសិក្សាលទ្ធភាពអាចធ្វើបានលើកទី១នោះ ត្រូវបានដកចេញវិញ អាស្រ័យដោយគ្មានលទ្ធពង្រីកដីដាំដុះ

❖ នៅខេត្តរតនគិរី សក្តានុពលដីដែលអាចដាំដុះកៅស៊ូបានមានចំនួនប្រហែល ៥ ០០០ហិកតា ស្ថិតនៅក្នុងស្រុកចំនួន៥ រួមមាន៖ ស្រុកអណ្តូងមាស លំផាត់ អូរយ៉ាដាវ បរកែវ និងអូរជុំ។ ចំពោះខេត្តបាត់ដំបង សក្តានុពលដីដែលអាចដាំដុះកៅស៊ូបានមានចំនួន ១ ០០០ហិកតា ស្ថិតក្នុងស្រុកចំនួន២ គឺស្រុកភ្នំព្រឹក និងស្រុកសំឡូត។ សក្តានុពលដីដែលអាចដាំដុះកៅស៊ូបាននៅក្នុងខេត្តទាំង ២នេះ គឺជាចំណែកដីដែលបច្ចុប្បន្នកំពុងដាំដំណាំរដូវនិងដំណាំកសិឧស្សាហកម្មផ្សេងទៀត ដូចជា ដំឡូងមី សណ្តែក ស្វាយចន្ទីជាដើម

❖ ដំណើរការនៃគម្រោងមានរយៈពេល ៧ឆ្នាំ ដែលគ្រោងដាំដុះលើផ្ទៃដីសរុបចំនួន ៦ ០០០ហិកតា (៥ ០០០ហិកតា ក្នុងខេត្តរតនគិរី និង ១ ០០០ ហិកតា ក្នុងខេត្តបាត់ដំបង)

❖ គោលបំណងសំខាន់នៃគម្រោង រួមមាន៖ (១) ធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅតាមទីតំបន់ជនបទតាមរយៈការបង្កើតការងារដល់គ្រួសារកសិករ (២)បង្កើនប្រភពប្រាក់ចំណូលដែលបានមកពីការធ្វើអាជីវកម្មកៅស៊ូដល់កសិករ និងជួយកាត់បន្ថយភាពក្រីក្រនៅតាមជនបទ (៣)បង្កើតប្រភពប្រាក់ចំណូលដល់ខឿនសេដ្ឋកិច្ចជាតិតាមរយៈការនាំចេញផលិតផលកៅស៊ូ និង (៤)ការពារបរិស្ថានទល់នឹងភាពហួតហែងក្តៅខ្លាំងនៃធម្មជាតិនិងទប់ស្កាត់ការហូរច្រោះដី។

❖ ដំណើរការនៃគម្រោង ត្រូវបានបែងចែកជា ៤ សមាសធាតុ រួមមាន៖ ១)សមាសភាគឥណទាន (A credit component) ២)សមាសភាគគាំទ្រជំនួយបច្ចេកទេស និងការកែច្នៃ (A component “Support to technical assistance and processing”) ៣)សមាសភាគគាំទ្រសហគមន៍កៅស៊ូគ្រួសារ (A component “support to rubber cooperatives”) និង ៤)សមាសភាគគ្រប់គ្រងគម្រោង និងគាំទ្រវិស័យកៅស៊ូ (A component “project management and support to the rubber sector”)

### ១)- សមាសភាគឥណទាន (A credit component)

✓ កម្ចីឥណទានដែលបានផ្តល់ឲ្យធនាគារអភិវឌ្ឍន៍ជនបទពី AFD មានចំនួន ១០,៨៥០លានដុល្លារ ជាកម្ចីដែលមានការប្រាក់ទាប សម្រាប់រយៈពេល ២០ឆ្នាំ និងមានរយៈពេលអនុគ្រោះ ៩ឆ្នាំ

✓ កម្ចីរបស់កសិករមានរយៈពេល ៦ឆ្នាំដំបូង សម្រាប់ដាំដុះកៅស៊ូ រួមមានការចំណាយទៅលើថ្លៃកូនកៅស៊ូ ការរៀបចំដី ជី ការធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី សេវាបច្ចេកទេស។ល។ កសិករត្រូវសងមកធនាគារវិញចាប់ពីឆ្នាំទី៨ បន្ទាប់ពីការដាំដុះ។ ដើម្បីទទួលបានកម្ចីឥណទាន កសិករត្រូវយកប័ណ្ណកម្មសិទ្ធិដីដែលបានដាំដុះកៅស៊ូទៅដាក់បញ្ចាំនៅធនាគារអភិវឌ្ឍន៍ជនបទ រហូតដល់ការសងត្រូវបានបញ្ចប់។

✓ កម្ចីឥណទានកសិករសម្រាប់ធ្វើការដាំដុះកៅស៊ូមានចំនួន ១ ៨០០ដុល្លារ/ហិកតា សម្រាប់ខេត្តរតនគិរី និងចំនួន ១ ៩២៥ដុល្លារ/ហិកតា សម្រាប់ខេត្តបាត់ដំបង។

✓ ចំណូលដុលជាមធ្យមបន្ទាប់ពីការបង់រំលោះ (Credit repayment) មានចំនួនប្រហែល ១០០០ដុល្លារ/ហិកតា សម្រាប់កសិករនៅខេត្តរតនគិរី និង ៨០០ដុល្លារ/ហិកតា សម្រាប់កសិករនៅខេត្តបាត់ដំបង។

### ២)-សមាសភាគគាំទ្រជំនួយបច្ចេកទេស និងការកែច្នៃ (A component “Support to technical assistance and processing”

✓ ការជ្រើសរើសកសិករដាំដុះត្រូវបានជ្រើសរើសដោយគណៈកម្មការមួយ រួមមាន៖ អ្នកបច្ចេកទេសសហគមន៍ និងរដ្ឋបាលឃុំ។ កសិករត្រូវមានផ្ទៃដីយ៉ាងតិច ២ហិកតា (ក្រៅពីដីព្រៃ) និងយ៉ាងហោចណាស់មានចំនួន ១ហិកតា សម្រាប់ដាំដុះកៅស៊ូដោយមានកម្មសិទ្ធិដីធ្លី ឬប័ណ្ណបញ្ជាក់កម្មសិទ្ធិដីចេញដោយឃុំ។ កសិករដាំដុះកៅស៊ូត្រូវមានកម្លាំងពលកម្មយ៉ាងតិចចំនួន២នាក់/គ្រួសារ និងមានទីលំនៅស្ថិតនៅក្នុងឃុំគោលដៅ។ ដីដាំដុះគួរតែជាដីអាចដាំដុះកៅស៊ូបាន និងមិនត្រូវស្ថិតនៅក្នុងតំបន់អភិរក្ស

✓ ទំហំផ្ទៃដីដាំដុះកៅស៊ូស្ថិតក្នុងចន្លោះពី ១ហិកតា ទៅ ៤ហិកតាយ៉ាងច្រើន។ ផ្ទៃដីដែលត្រូវបង្វែរដាំដុះកៅស៊ូមិនត្រូវឲ្យលើសពី ៥០% នៃផ្ទៃដីចម្ការសរុប ដើម្បីឲ្យកសិករដាំដំណាំផ្សេងក្រៅពីកៅស៊ូ

✓ គម្រោងនឹងផ្តល់រុក្ខសម្ភារមានគុណភាពខ្ពស់ ជាតុចូល និងសេវាបច្ចេកទេស ដល់កសិករដាំដុះកៅស៊ូតាមរយៈកម្ចីឥណទានពីធនាគារ និងត្រូវសងមកវិញ នៅពេលកៅស៊ូផ្តល់ផល ចាប់ពីឆ្នាំទី៨ ដល់ឆ្នាំទី១៦

✓ ចំពោះខេត្តបាត់ដំបង កសិករដាំដុះកៅស៊ូត្រូវបង់ថ្លៃសេវាបច្ចេកទេស ដោយបន្ថយពីចំនួន ៤៩ ដុល្លារ/ហិកតា សម្រាប់ឆ្នាំទី១ ដល់ឆ្នាំទី៤ មកចំនួន ១២ដុល្លារ/ហិកតា សម្រាប់ឆ្នាំទី៥ និងទី៦។ ចំពោះខេត្តរតនគិរី កសិករដាំដុះកៅស៊ូត្រូវបង់ថ្លៃសេវាបច្ចេកទេសដោយបន្ថយពីចំនួន ៨៩ដុល្លារ/ហិកតា សម្រាប់ឆ្នាំទី១-ឆ្នាំទី៤ មក ២២ដុល្លារ/ហិកតា សម្រាប់ឆ្នាំទី៥ និងទី៦។ ការបង់សេវារបស់កសិករនៅឆ្នាំទី១-ឆ្នាំទី៤ មានតម្លៃខ្ពស់ជាងឆ្នាំទី៥ និងទី៦ អាស្រ័យដោយអ្នកបច្ចេកទេសត្រូវចុះពិនិត្យ និងណែនាំដល់កសិករជាប្រចាំ។

### ៣) សមាសភាគគាំទ្រសហគមន៍កៅស៊ូគ្រួសារ (A component “support to rubber cooperatives ”)

✓ គម្រោងនឹងរៀបចំគាំទ្រក្នុងការបង្កើតសហគមន៍កៅស៊ូគ្រួសារនៅតាមឃុំ ស្រុក ដោយសហការជាមួយជំនាញពាក់ព័ន្ធក្នុងដំណើរការនៃការបង្កើតសហគមន៍ក្នុងគោលបំណង ដើម្បីឲ្យសហគមន៍គ្រប់គ្រងបន្តនៅពេលគម្រោងត្រូវបានបញ្ចប់

✓ ខេត្តរតនគិរី សហគមន៍កៅស៊ូគ្រួសារថ្នាក់ស្រុកត្រូវបង្កើតចំនួន ៥ និងថ្នាក់ឃុំមានចំនួន ២០។ ចំពោះខេត្តបាត់ដំបង សហគមន៍កសិករកៅស៊ូគ្រួសារថ្នាក់ស្រុកត្រូវបង្កើតចំនួន២ និងថ្នាក់ឃុំមានចំនួន៤

✓ ក្នុងករណីកសិករ ដែលមិនបានធ្វើការថែទាំលើចម្ការរបស់ខ្លួន សហគមន៍ជាអ្នកទទួលខុសត្រូវក្នុងការកាន់កាប់ចម្ការកៅស៊ូបន្ត (ការថែទាំនិងការប្រមូលផល)។

### ៤) សមាសភាគគ្រប់គ្រងគម្រោង និងគាំទ្រវិស័យកៅស៊ូ ( A component “project management and support to the rubber sector)

ដើម្បីឲ្យដំណើរការនៃការអភិវឌ្ឍន៍កៅស៊ូបានល្អ គម្រោងនឹងរៀបចំអង្គភាពគ្រប់គ្រងគម្រោង (PMU) ប្រព័ន្ធវាយតម្លៃនៃការគ្រប់គ្រង សិក្សាទីផ្សារកៅស៊ូ គាំទ្រផ្តល់វិញ្ញាបនប័ត្រច្បារពូជកៅស៊ូ សកម្មភាពការងារស្រាវជ្រាវកៅស៊ូរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា គាំទ្រការបង្កើតសាខាធនាគារអភិវឌ្ឍន៍ជនបទចំនួន ២ ដែលបានជ្រើសរើសនិងសិក្សាតំបន់ដាំដុះថ្មីនៃគម្រោង។

ក្រោយពីការធ្វើបទបង្ហាញ អង្គប្រជុំបានពិភាក្សាគ្នានូវចំណុចមួយចំនួនដូចខាងក្រោម៖

✓ ចំពោះទិន្នផលកៅស៊ូប្រចាំឆ្នាំដែលគម្រោងគ្រោងចំនួន១,២តោន/ហិកតា គួរតែបង្កើនដល់ ១,៤តោន/ហិកតា ឬ១,៥តោន/ហិកតា អាស្រ័យដោយរុក្ខសម្ភារ

មានគុណភាពខ្ពស់ និងចម្ការមានការថែទាំត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសក្រោមការគាំទ្រដោយគម្រោង

✓ ចំពោះអត្រាការប្រាក់ចំនួន ១០,៥%/ឆ្នាំ ដែលកសិករខ្ចីគួរពិចារណានិងបន្ថយឲ្យបានកម្រិតអប្បបរមាដែលអាចធ្វើទៅបាន

✓ ចំពោះការសងរំលោះគួរតែបន្ថយពី ៣០% មក ២៥% នៃប្រាក់ចំណូលដុល ចាប់ពីឆ្នាំទី ៥ឡើងទៅ

✓ ចំពោះជំនាញការបច្ចេកទេស សម្រាប់ខេត្តទាំង ០២ គួរតែជ្រើសរើសចេញពីក្រុមហ៊ុនតែមួយ ដើម្បីឲ្យមានលក្ខណៈប្រព័ន្ធគ្រប់គ្រងតែមួយ។



*ទិដ្ឋភាពនៃកិច្ចប្រជុំ*



*ទិដ្ឋភាពនៃកិច្ចប្រជុំ*

# ព័ត៌មានអន្តរជាតិ

## របាយការណ៍ស្តីពី និន្នាការ & ស្ថិតិ កៅស៊ូធម្មជាតិ របស់សមាគម ANRPC

*ដកស្រង់ពីព្រឹត្តបត្រ ANRPC ប្រចាំខែមករា ឆ្នាំ២០១៧*
*ប្រែសម្រួលដោយលោក **កែវ សំអុន***
*អនុប្រធាននាយកដ្ឋានទីផ្សារ&សហប្រតិបត្តិការអន្តរជាតិ*

### ១.ផលិតកម្មកៅស៊ូធម្មជាតិ

ផ្អែកតាមតួលេខពិតប្រាកដ រហូតដល់ខែវិច្ឆិកា និងការព្យាករណ៍បឋម សម្រាប់ខែធ្នូ បានឲ្យដឹងថា ប្រទេសជាសមាជិកនៃសមាគម ANRPC ផលិតបានកៅស៊ូធម្មជាតិប្រមាណ ១០,៧៤៦លានតោន ក្នុងឆ្នាំ ២០១៦ ក្នុងកម្រិតអត្រាថយចុះប្រហែល ២,៧% ធៀបនឹងឆ្នាំមុន។ ការធ្លាក់ចុះផលិតកម្មបន្ថែមក្នុងឆ្នាំ ២០១៦ គឺដោយសារការពិនិត្យកែសម្រួលទិន្នផលឡើងវិញ ដែលបានធ្វើឡើងដោយប្រទេសវៀតណាម ឥណ្ឌា និងម៉ាឡេស៊ី។

ខណៈពេលដែលផលិតកម្មកៅស៊ូធម្មជាតិ បានកើនឡើងក្នុងប្រទេសជាសមាជិកនៃសមាគម ANRPC ចំនួន ០៤ រួមមាន៖ ឥណ្ឌូនេស៊ី(០,៤%) វៀតណាម(១,៥%) ឥណ្ឌា(៧,៨%) និងកម្ពុជា (១៧,៣%) សម្រាប់ឆ្នាំ២០១៦នេះ បណ្តាប្រទេសជាសមាជិកនៃសមាគម ANRPC ចំនួន ៥ ផ្សេងទៀត មាននិន្នាការធ្លាក់ចុះក្នុងផលិតកម្មកៅស៊ូធម្មជាតិរបស់ខ្លួនទៅវិញគឺ៖ ប្រទេសថៃ(-៦,៥%) ចិន(-២,៥%) ម៉ាឡេស៊ី (-១០,០%) ហ្វីលីពីន(-០,៤%) និងប្រទេសលង្កា (-១០,៣%)។

ទោះជាយ៉ាងណា ផលិតកម្មកៅស៊ូធម្មជាតិនៃបណ្តាប្រទេសជាសមាជិកនៃសមាគម ANRPC ត្រូវបានគេរំពឹងថា នឹងកើនឡើងក្នុងអត្រាប្រមាណ ៤,៤% ស្មើនឹង ១១,២២២លានតោន ក្នុងអំឡុងឆ្នាំ២០១៧នេះ បើផ្អែកលើមូលដ្ឋាននៃការព្យាករណ៍ប្រចាំឆ្នាំ គួបផ្សំនឹងផ្ទៃដីកំពុងចៀរ ដែលបានរំពឹងទុកចំនួន ៩,១១៦លានហិកតាផងនោះ។ ប្រទេសភាគច្រើនត្រូវបានគេរំពឹងថានឹងបង្កើនការផលិតរបស់ខ្លួន រួមមានប្រទេសថៃ(៤,៧%) វៀតណាម(៦,៧%) ចិន(៨,៥%) ម៉ាឡេស៊ី(៤,៥%) ឥណ្ឌា(៤,៨%) កម្ពុជា(៣៧,២%) ហ្វីលីពីន(៧,៨%) និងប្រទេសស្រីលង្កា(៦,៩)។ ដោយឡែក ឥណ្ឌូនេស៊ី គឺជាប្រទេសតែមួយគត់ដែលបានព្យាករណ៍ថា មានការធ្លាក់ចុះផលិតកម្មកៅស៊ូធម្មជាតិរបស់ខ្លួនពីបរិមាណ ៣,១៥៨លានតោន នាឆ្នាំ ២០១៦ មកត្រឹម ៣,១៥០លានតោនក្នុងឆ្នាំ២០១៧។

ផ្អែកលើការប៉ាន់ស្មានបឋម បានឲ្យដឹងថា ផលិតកម្មកៅស៊ូធម្មជាតិ បានធ្លាក់ចុះដល់ ៩២២០០០តោន ក្នុងអំឡុងខែមករា ឆ្នាំ២០១៧ ក្នុងអត្រាប្រមាណ ៨,៤% ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ។ ការកាត់បន្ថយផលិតកម្មនេះ គឺដោយសារគ្រោះទឹក

ជំនន់ដ៏ធ្ងន់ធ្ងរ នៅភូមិភាគខាងត្បូងប្រទេសថៃដែលប៉ះពាល់ដល់ទិន្នផលរបស់ប្រទេស រួមទាំងបណ្ដាប្រទេសផលិតកៅស៊ូធម្មជាតិភាគច្រើន បានចាប់ផ្ដើមចូលដល់រដូវផ្អាកចៀរជ័រផងដែរ។

យោងតាមប្រភពព័ត៌មានពីអាជ្ញាធរកៅស៊ូថៃ បានធ្វើការប៉ាន់ប្រមាណត្រួសៗថា ផ្ទៃដីឲ្យផលប្រហែល ១០០ ០០០ហិកតា ត្រូវទុកចោលមិនបានចៀរ ដែលជាលទ្ធផលអាចនឹងប៉ះពាល់ដល់ការកាត់បន្ថយការផលិតកៅស៊ូក្នុងអត្រាប្រមាណ ១០% នាអំឡុងពេលគ្រោះទឹកជំនន់នេះ។

ផ្អែកលើមូលដ្ឋាននៃការព្យាករណ៍ប្រចាំឆ្នាំបានឲ្យដឹងថា ទោះបីជាផលិតកម្មកៅស៊ូធម្មជាតិមានការធ្លាក់ចុះ ក្នុងអំឡុងខែមករា ឆ្នាំ២០១៧នេះ ក៏ដោយក៏ការផលិតក្នុងត្រីមាសទី១ ឆ្នាំ២០១៧ ត្រូវបានគេរំពឹងថា នឹងកើនឡើងបន្តិច ក្នុងកម្រិតអត្រា ០,២% ជាមួយនឹងបរិមាណដល់ទៅ ២,៤៦៦លានតោន។ ផលិតកម្មកៅស៊ូធម្មជាតិ ត្រូវបានគេព្យាករណ៍ផងដែរថា នឹងកើនឡើងដល់ ៧៤៦.០០០តោន នាអំឡុងខែមេសា ឆ្នាំ២០១៧ ក្នុងអត្រាកំណើនប្រមាណ ៩,៩% ធៀបទៅនឹងរយៈពេលដូចគ្នា កាលពីឆ្នាំ២០១៦។

ក្រុមប្រឹក្សាកៅស៊ូប្រទេសឥណ្ឌា បានរាយការណ៍ថា ផ្ទៃដីឲ្យផលប្រហែល ២៥% ក្នុងប្រទេសឥណ្ឌា បានត្រូវទុកចោលមិនបានចៀរ ក្នុងអំឡុងខែមករា ឆ្នាំ២០១៧ ដោយសារតម្លៃនៅតែមិនទាន់មានការទាក់ទាញទៅដល់កសិករដាំកៅស៊ូក្នុងស្រុក។

## ២.ការប្រើប្រាស់កៅស៊ូធម្មជាតិ

ប្រទេសជាសមាជិកនៃសមាគម ANRPC បានប្រើប្រាស់ផលិតផលកៅស៊ូប្រមាណ ៨,០៤២លានតោន ក្នុងឆ្នាំ២០១៦ ពោលគឺកើនឡើង ក្នុងអត្រាប្រហែល ៥,៣% ធៀបនឹងឆ្នាំ២០១៥។ កំណើននេះត្រូវបានផ្អែកលើតួលេខពិតប្រាកដ មកដល់ត្រឹមខែវិច្ឆិកា គួបផ្សំនឹងការប៉ាន់ស្មានបឋមសម្រាប់ខែធ្នូផង។ តម្រូវការកៅស៊ូធម្មជាតិពិភពលោកប្រហែល ៦៥% ត្រូវបានប្រើប្រាស់ក្នុងប្រទេសជាសមាជិកនៃសមាគម ANRPC ដោយឡែកក្នុងឆ្នាំ២០១៦ ប្រទេសធំពីរ គឺចិននិងឥណ្ឌា បានប្រើប្រាស់ផលិតផលកៅស៊ូប្រមាណ ៥,៩១១លានតោន ដែលមានការកើនឡើងពីឆ្នាំមុន ក្នុងបរិមាណដល់ទៅ ២៣៨.០០០តោន។

ក្នុងអំឡុងឆ្នាំ២០១៧ ប្រទេសជាសមាជិកនៃសមាគម ANRPC ត្រូវបានរំពឹងថា នឹងមានកំណើនប្រើប្រាស់ក្នុងអត្រាប្រមាណ ១,៨% ជាមួយនឹងបរិមាណដល់ទៅ ៨,១៨៩លានតោន ធៀបនឹងឆ្នាំ២០១៦។ ប្រទេសចិនរំពឹងថា នឹងមានការប្រើប្រាស់កៅស៊ូធម្មជាតិក្នុងបរិមាណប្រហែល ៤,៨៩០លានតោន ខណៈដែលប្រទេសឥណ្ឌា នឹងមានតម្រូវការប្រើប្រាស់កៅស៊ូធម្មជាតិក្នុងបរិមាណប្រហែលតែ ១,០៦០លានតោន ក្នុងអំឡុងឆ្នាំ២០១៧ ប៉ុណ្ណោះ។

បើទោះបីជា ប្រទេសប្រើប្រាស់ធំចម្បងទាំងពីរលំដាប់ពិភពលោកនឹងមានកំណើនក្នុងការប្រើប្រាស់កើនឡើងក៏ដោយ ក៏បណ្ដាប្រទេសជាសមាជិកនៃសមាគម ANRPC រំពឹងថានឹងមានកំណើនវិជ្ជមានក្នុងការប្រើប្រាស់កៅស៊ូធម្មជាតិផងដែរ លើកលែងតែប្រទេសម៉ាឡេស៊ី។

តាមការសង្កេតមួយផ្សេងទៀត បានបង្ហាញថា កំណើននៃការប្រើប្រាស់ក្នុងបណ្តាប្រទេសនាំចេញកៅស៊ូធម្មជាតិ ក៏ត្រូវបានគេរំពឹងថានឹងកើនឡើងលឿនជាង ប្រទេសចិននិងឥណ្ឌាទៅទៀត។

ផ្អែកទៅតាមការប៉ាន់ស្មានបឋម សម្រាប់ខែមករា ឆ្នាំ២០១៧ បានឲ្យដឹងថា ការប្រើប្រាស់កៅស៊ូធម្មជាតិដោយបណ្តាប្រទេសជាសមាជិកនៃសមាគម ANRPC ទំនងជានឹងទាបជាង ក្នុងបរិមាណត្រឹម ៥៧២០០០តោន នាអំឡុងខែមករា ឆ្នាំ២០១៧ ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ ដែលមានបរិមាណដល់ទៅ ៦៥៣ ០០០តោន។ បញ្ហានេះ គឺបណ្តាលមកពីសកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះ គួបផ្សំជាមួយនឹងការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីរបស់សហគមន៍ជនជាតិចិនផងនោះ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ការប្រើប្រាស់កៅស៊ូធម្មជាតិ ត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងអត្រា ២,២% ស្មើទៅនឹងបរិមាណ ១,៩៤៣លានតោន ក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០១៧នេះ។ ក៏ប៉ុន្តែ ផ្អែកលើតួលេខព្យាករណ៍បានបង្ហាញថា ការប្រើប្រាស់កៅស៊ូធម្មជាតិ ត្រូវបានរំពឹងទុកថានឹងមាននិន្នាកាធ្លាក់ចុះបន្តិច ក្នុងអត្រាប្រមាណ ០,៧% ក្នុងខែមេសា ឆ្នាំ២០១៧។

## ៣.នីយាំរណ័កម្មកៅស៊ូធម្មជាតិ

ផ្អែកលើមូលដ្ឋាននៃការព្យាករណ៍ប្រចាំឆ្នាំ បានឲ្យដឹងថា ទំហំនៃការនាំចេញផលិតផលកៅស៊ូធម្មជាតិសរុប ដែលបានចុះបញ្ជីដោយប្រទេសជាសមាជិកនៃសមាគម ANRPC ក្នុងអំឡុងឆ្នាំ២០១៦ មានទំហំប្រមាណ ៨,៧៦១លានតោន និងបានធ្លាក់ចុះក្នុងកម្រិតអត្រា ៣,០%។ ការព្យាករណ៍នេះ បានធ្វើឡើងដោយផ្អែកលើតួលេខពិតប្រាកដមកដល់ត្រឹមខែវិច្ឆិកា គួបផ្សំនឹងការប៉ាន់ស្មានបឋមសម្រាប់ខែធ្នូផង។ ទំហំនៃការនាំចេញផលិតផលកៅស៊ូធម្មជាតិសរុប គឺបានរួមបញ្ចូលទាំងការនាំចេញទៅកាន់ប្រទេសចិននូវប្រភេទផលិតផលកៅស៊ូសមាស Compound rubber ( HS 400510, 400520, 400591, 400599) និងប្រភេទកៅស៊ូចម្រុះ Mixture rubber ( HS 400280)ផងដែរ។

ការនាំចេញក្នុងចំណោមប្រទេសជាសមាជិកនៃសមាគម ANRPC ត្រូវបានគេរំពឹងថា នឹងកើនឡើងដល់បរិមាណ ៨,៩៨៥លានតោន ពោលគឺកើនឡើងក្នុងអត្រាប្រហែល ២,៦% ក្នុងឆ្នាំ២០១៧ ធៀបទៅនឹងឆ្នាំមុន។ កំណើនវិជ្ជមាននៃការនាំចេញត្រូវបានគេរំពឹងទុកភាគច្រើននៅក្នុងប្រទេសជាសមាជិកនៃសមាគម ANRPC លើកលែងតែប្រទេសវៀតណាម ដែលអាចនឹងមានការធ្លាក់ក្នុងអត្រាប្រមាណ ៤,៣% ក្នុងអំឡុងឆ្នាំ២០១៧នេះ។

នៅក្នុងខែមករា ឆ្នាំ២០១៧ ការនាំចេញបានកើនឡើង ក្នុងកម្រិតអត្រា ៣,១% ដែលមានបរិមាណដល់ទៅ ៧០៥ ០០០តោន ធៀបទៅនឹងខែមករា ឆ្នាំ២០១៦។ ជាមួយគ្នានេះដែរ ក៏មានការប្រមើលទុកថានឹងមានការធ្លាក់ចុះបន្តិច ក្នុងការនាំចេញកៅស៊ូធម្មជាតិក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០១៧ ក្នុងអត្រាធ្លាក់ចុះប្រមាណ ២,៧% ដែលមានបរិមាណនាំចេញត្រឹមតែ ២,១១១លានតោន ធៀបនឹងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន។ បើតាមតួលេខព្យាករណ៍ ដែលបានផ្តល់ឱ្យដោយប្រទេសជាសមាជិកនៃសមាគម ANRPC សម្រាប់ខែនេះ បានឲ្យដឹងថា ទោះជាយ៉ាងណាក៏ការនាំចេញ

ត្រូវបានរំពឹងថា នឹងមានកំណើនក្នុងអត្រា ៣,០% ជាមួយបរិមាណដល់ទៅ ៧៦០.០០០តោន ក្នុងអំឡុងខែមេសា ឆ្នាំ២០១៧ខាងមុខ។

## ៤.អាហរណ៍កម្មកៅស៊ូធម្មជាតិ

ការនាំចូលផលិតផលកៅស៊ូធម្មជាតិសរុបដោយបណ្តាប្រទេសជាសមាជិកនៃសមាគម ANRPC បានស្ថិតក្នុងបរិមាណ ៦,១២៩លានតោន ពោលគឺកើនឡើង ក្នុងអត្រាដល់ទៅ ១,៩% ក្នុងអំឡុងឆ្នាំ២០១៦ ធៀបទៅនឹងឆ្នាំមុន។ បរិមាណសរុបនេះគឺបានរាប់បញ្ចូលទាំងការនាំចូលទៅកាន់ប្រទេសចិននូវប្រភេទផលិតផលកៅស៊ូសមាស Compound rubber (HS 4005.10, 4005.20, 4005.91, 4005.99) និងប្រភេទកៅស៊ូចម្រុះ Mixture rubber (HS 4002.80) ផងដែរ។ នាអំឡុងឆ្នាំ២០១៦ ប្រទេសម៉ាឡេស៊ីជាប្រទេសតែមួយគត់ដែលបានបញ្ជាក់ពីការនាំចូលធ្លាក់ចុះក្នុងអត្រាប្រមាណ ៥,២% ជាមួយបរិមាណដល់ទៅ ៩២៥ ០០០តោន ធៀបទៅនឹងឆ្នាំ២០១៥។

បើទោះជាការនាំចូលធ្លាក់ចុះដោយសារប្រទេសម៉ាឡេស៊ីក៏ដោយក៏ប្រទេសចិនបានបង្ហាញថា បរិមាណផលិតផលកៅស៊ូ ៤,១៥១លានតោន បាននិងកំពុងនាំចូលមកកាន់ប្រទេសនេះ ក្នុងអត្រាកំណើនពីឆ្នាំមុនប្រមាណ ១,២%។ ដូចគ្នានេះផងដែរ ប្រទេសឥណ្ឌាបាននាំចូលកៅស៊ូធម្មជាតិ ក្នុងបរិមាណ ៤៦០ ០០០តោន ដែលមានអត្រាកំណើន ២,២% ធៀបនឹងឆ្នាំមុន។ ការព្យាករណ៍ទាំងនេះ គឺជាការសង្កេតបឋម ដោយផ្អែកជាមូលដ្ឋានលើតួលេខពិតប្រាកដ គិតមកដល់ត្រឹមខែវិច្ឆិកា គួបផ្សំនឹងការប៉ាន់ស្មានបឋម សម្រាប់ខែធ្នូ ឆ្នាំ២០១៦ផង។

ការនាំចូលកៅស៊ូធម្មជាតិដោយបណ្តាប្រទេសជាសមាជិកនៃសមាគម ANRPC អាចនឹងមានទំហំទាបជាងកាលពីឆ្នាំ២០១៦ ក្នុងបរិមាណប្រហែល ៦,១២៩លានតោន មកត្រឹមបរិមាណ ៦,០៦៨លានតោន ក្នុងអំឡុងឆ្នាំ២០១៧ ខណៈដែលការនាំចូលអាចនឹងធ្លាក់ចុះ ៧,៤% ក្នុងប្រទេសម៉ាឡេស៊ី ៨,៧% ក្នុងប្រទេសឥណ្ឌា ២៣,១% ក្នុងប្រទេសវៀតណាម និង ៧,៤% ក្នុងប្រទេសផ្សេងៗទៀត។ ប្រទេសចិនដែលជាអ្នកនាំចូលកៅស៊ូធម្មជាតិធំបំផុតលំដាប់ពិភពលោក រំពឹងថានឹងនាំចូលផលិតផលកៅស៊ូធម្មជាតិប្រមាណ ៤,៣០៤លានតោន ក្នុងអត្រាកំណើន ៣,៧% នាអំឡុងឆ្នាំ២០១៧ ធៀបទៅនឹងឆ្នាំមុន។

ការនាំចូលដែលបានចុះបញ្ជី បង្ហាញនូវកំណើនអវិជ្ជមាន ក្នុងកម្រិតអត្រាប្រមាណ ១០,៩% នាអំឡុងខែមករា ឆ្នាំ២០១៧។ បើទោះជា ការនាំចូលមានការធ្លាក់ចុះ ក្នុងអំឡុងខែមករាឆ្នាំ២០១៧ ក៏ដោយក៏ការនាំចូលសរុបដោយប្រទេសជាសមាជិកនៃសមាគម ANRPC សម្រាប់ត្រីមាសទី១ នៃឆ្នាំ២០១៧ ត្រូវបានរំពឹងថានឹងកើនឡើងក្នុងអត្រា ១,៦% ដែលមានបរិមាណ ១,៤៩៧លានតោន ធៀបនឹងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០១៦។ ក៏ប៉ុន្តែ ផ្អែកលើមូលដ្ឋានព្យាករណ៍ប្រចាំឆ្នាំ ការនាំចូលកៅស៊ូធម្មជាតិ ត្រូវបានរំពឹងថានឹងធ្លាក់ចុះបន្តិចនៅក្នុងខែមេសា ឆ្នាំ២០១៧ ក្នុងអត្រាប្រមាណ ៣,៤% ដែលមានបរិមាណ ៤៨២ ០០០តោន។

## ៥.ការពិនិត្យឡើងវិញអំពីការអភិវឌ្ឍនៅក្នុងទីផ្សារផលិតផលកៅស៊ូធម្មជាតិ

ការកែលម្អជាប្រចាំ ត្រូវបានគេសង្កេតលើតម្លៃនៃកៅស៊ូធម្មជាតិនៅទូទាំងទីផ្សារជួញដូរសំខាន់ៗ ចាប់ពីចុងឆ្នាំ២០១៦មក។ នៅខែមករា ឆ្នាំ២០១៧ តម្លៃកៅស៊ូដុំដែលបានជួញដូរមានភាពប្រសើរជាខែមុនក្នុងអត្រា ១៣,៥% ក្នុងទីផ្សារនៅទីក្រុងកូឡាឡាំពួរ និង ១៥,៣% ក្នុងទីផ្សារកៅស៊ូនាទីក្រុងបាងកក។ សម្រាប់ទីផ្សារកៅស៊ូសន្លឹក តម្លៃនៃកៅស៊ូសន្លឹកប្រភេទលេខ៣ (RSS3) បានកើនឡើងក្នុងអត្រា ១៦,៧% ក្នុងទីផ្សារនៅទីក្រុងបាងកក និងកៅស៊ូសន្លឹកប្រភេទលេខ៤ (RSS4) បានកើនឡើង ក្នុងអត្រា ៩,១% នៅក្នុងទីផ្សារកៅស៊ូ នៃប្រទេសឥណ្ឌា។

ភាពប្រសើរឡើងនៃតម្លៃកៅស៊ូ ក្នុងអំឡុងខែមករា ឆ្នាំ២០១៧ គឺដោយសារមានការព្រួយបារម្ភលើការផ្គត់ផ្គង់ ដែលបានរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់នៅក្នុងប្រទេសថៃ គួបផ្សំនឹងដើមរដូវផ្អាកចៀរជ័រនៅក្នុងបណ្តាប្រទេសផលិតករកៅស៊ូធម្មជាតិសំខាន់ៗផងនោះ។

ក្នុងអំឡុងខែមករាឆ្នាំ២០១៧ តម្លៃកៅស៊ូត្រូវបានសង្កេតឃើញថា មាននិន្នាការកើនឡើង បើទោះបីជា តម្លៃប្រេងឆៅបានធ្លាក់ចុះខ្លាំង នាអំឡុងដើមខែនៃឆ្នាំនេះក៏ដោយ។ តម្លៃប្រេងឆៅមានតម្លៃស្ថេរភាពប្រហែល៥០អាម៉េរិក/បារ៉ែល។ តាមសេចក្តីរាយការណ៍របស់ទីភ្នាក់ងារថាមពលអន្តរជាតិ( IEA) បានឲ្យដឹងថា ការងើបឡើងតម្លៃប្រេងឆៅ គឺអនុលោមទៅតាមអ្វីដែលអង្គការ OPEC បានធ្វើការព្រមព្រៀងក្នុងការកាត់បន្ថយទិន្នផលរបស់ខ្លួន ចាប់ពីខែមករា ឆ្នាំ២០១៧។ ទីភ្នាក់ងារថាមពលអន្តរជាតិ (IEA) បានបន្តលើកឡើងទៀតថា ជាមួយនឹងកម្រិតអនុលោមភាព ដែលអង្គការ (OPEC) អាចនឹងសន្យាបាននេះ បាននាំឲ្យបរិមាណអតិរេកប្រេងឆៅអាចនឹងត្រូវបានកាត់បន្ថយក្នុងបរិមាណ ៦00 000បារ៉ែល/ថ្ងៃ សម្រាប់រយៈពេល ៦ខែ។

នៅក្នុងព្រឹត្តិបត្រ «*ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក*» ដែលបានចេញផ្សាយថ្មីៗដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងខែមករាឆ្នាំ២០១៧ បានព្យាករណ៍ឲ្យដឹងថា សេដ្ឋកិច្ចពិភពលោកនៅតែរក្សាកំណើនរបស់ខ្លួន ក្នុងកម្រិតអត្រា ៣,៤% សម្រាប់ឆ្នាំ២០១៧ ដដែល។

ទស្សនវិស័យសេដ្ឋកិច្ចដ៏ត្រចេះត្រចង់ជាងមុនក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿននិងប្រទេសដែលមានទីផ្សារសមាហរណកម្មថ្មីៗ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ គឺមានកំណើនក្នុងអត្រា ១,៩% និង ៤,៥% រៀងៗគ្នា ក្នុងឆ្នាំ២០១៧ ដែលនឹងអាចបង្កើតឱ្យមានការយល់ឃើញជាវិជ្ជមានមួយចំនួនទៅលើទីផ្សារពិភពលោក ជាពិសេស ទីផ្សារឧស្សាហកម្មកៅស៊ូធម្មជាតិ។

កំណើន ៤,៥% ក្នុងទីផ្សារសមាហរណកម្មថ្មីៗ រួមទាំងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ នឹងជំរុញបន្ថែមទៀតលើការព្យាករណ៍ជាសកល ក្នុងឆ្នាំ២០១៧។ ផ្អែកលើទស្សនវិស័យសេដ្ឋកិច្ចពិភពលោក (WEO) របស់ IMF ដែលបានចេញផ្សាយ នៅក្នុងខែមករា ឆ្នាំ២០១៧ បានឲ្យដឹងថា ជាមួយនឹងការបន្តគោលនយោបាយជំរុញលើកទឹកចិត្តនៅក្នុងប្រទេសចិន អត្រាកំណើនរបស់ប្រទេសនេះ សង្ឃឹមថានឹងខ្លាំងជាងការរំពឹងទុក។

ទីផ្សារហ៊ុនតូក្យូ TOCOM សម្រាប់កិច្ចសន្យាទិញ-លក់នាពេលអនាគត បានត្រូវគេសង្កេតឃើញថា កៅស៊ូសន្លឹកប្រភេទ RSS 3 មាននិន្នាការកើនឡើងក្នុងអំឡុងខែមករា ឆ្នាំ២០១៧ បើទោះជា ប្រាក់យ៉េនរបស់ជប៉ុនមានតម្លៃខ្ពស់តិចតួចរហូតដល់ចុងខែមករានេះក៏ដោយ។

ខណៈពេលដែលទីផ្សារហ៊ុន នៅក្នុងប្រទេសចិននិងសិង្ហបុរីត្រូវបានបិទទ្វារ ក្នុងអំឡុងពេលថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំថ្មី វិនិយោគិនជាច្រើនបានបង្វែរសកម្មភាពខ្លួនទៅកាន់ទីផ្សារហ៊ុន TOCOM ដោយសារមានតែទីផ្សារហ៊ុននេះមួយគត់បើកដំណើរការក្នុងអំឡុងរដូវបុណ្យនេះ។ ទង្វើនេះបានបណ្តាលឱ្យតម្លៃកៅស៊ូសន្លឹកប្រភេទ RSS 3 ក្នុងទីផ្សារហ៊ុនតូក្យូ TOCOM សម្រាប់កិច្ចសន្យាទិញ-លក់នាពេលអនាគត បានកើនឡើង ៦% អំឡុងពេល ៣ថ្ងៃ ក្នុងតម្លៃ ៣៥១,៩យ៉េន/គីឡូក្រាម សម្រាប់ថ្ងៃជួញដូរចុងក្រោយលើកទីពីរនៃខែមករា។

សរុបសេចក្តីមក ក្តីព្រួយបារម្ភលើការផ្គត់ផ្គង់ផលិតផលកៅស៊ូធម្មជាតិ ដែលបណ្តាលមកពីគ្រោះទឹកជំនន់ក្នុងប្រទេសថៃ និងការចាប់ផ្តើមរដូវផ្អាកចៀរជ័រ គឺជាកំណើនអវិជ្ជមានដែលមានកម្រិតអត្រាប្រមាណ ៨,៤% ក្នុងការផលិតកៅស៊ូធម្មជាតិរបស់បណ្តាប្រទេសជាសមាជិកនៃសមាគម ANRPC នាអំឡុងខែមករា ឆ្នាំ២០១៧។ តាមការព្យាករណ៍របស់ IMF បានបង្ហាញថា និន្នាការកើនឡើងតម្លៃកៅស៊ូធម្មជាតិក្នុងអំឡុងខែមករា ឆ្នាំ២០១៧ ត្រូវបានគាំទ្រជាចម្បងដោយមូលដ្ឋានគ្រឹះទីផ្សាររឹងមាំនៅក្នុងទីផ្សារកៅស៊ូធម្មជាតិ និងមួយផ្នែកមកពីការធ្លាក់ថ្លៃប្រាក់យ៉េនរបស់ជប៉ុន គួបផ្សំនឹងទស្សនវិស័យសេដ្ឋកិច្ចប្រសើរឡើង។

ផ្អែកតាមរបាយការណ៍របស់ IMF បានឲ្យដឹងថា កំណើនសេដ្ឋកិច្ចពិភពលោកអាចនឹងត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈគោលនយោបាយ ដែលនឹងជំរុញកំណើនប្រកបដោយនិរន្តរភាព និងពេញលេញគួបផ្សំនឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលផងដែរ។

លើសពីនេះទៀត មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានប្រមើលមើលទុកជាមុនផងដែរថា ទីផ្សារសមាហរណកម្មថ្មីៗ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍ នៅតែជាកត្តាជំរុញចម្បង សម្រាប់ការព្យាករណ៍លើកំណើនសេដ្ឋកិច្ចពិភពលោក ហេតុនេះ វាអាចផ្តល់នូវការយល់ឃើញដ៏ល្អ ក្នុងការអភិវឌ្ឍលើវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ។

## អ្នកវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យ Minnesota បង្កើតនូវកៅស៊ូសំយោគធម្មជាតិ (Natural synthetic Rubber)

*ប្រភព៖ www.tyrepress.com*
*ផ្សាយចេញថ្ងៃ២៧ ខែកុម្ភៈ ឆ្នាំ២០១៧*
*ប្រែសម្រួលដោយលោក **គុយ គគ្គី***

យោងតាមរបាយការណ៍ ការិយាល័យបច្ចេកទេសនិងពាណិជ្ជូបនីយកម្មនៃសាកលវិទ្យាល័យ Minnesota បានដាក់សំណើប្រកាសនីយបត្រតក្កកម្ម (Petent) ដើម្បីអាចបន្តបច្ចេកទេសនិងគម្រោងផ្នែកកៅស៊ូ និង

ដើម្បីប្រគល់សិទ្ធិបច្ចេកទេសទៅឲ្យក្រុមហ៊ុនណាដែលចាប់អារម្មណ៍លើមុខជំនួញនេះ។ នៅថ្ងៃទី៨ ខែកុម្ភៈ ក្រុមអ្នកស្រាវជ្រាវ ដែលដឹកនាំដោយសាកលវិទ្យាល័យ Minnesota បានប្រកាសថា «ពួកគេបានបង្កើតបច្ចេកទេសថ្មីមួយ ដើម្បីផលិតសំបកកង់យានយន្តពីដើមឈើនិងស្មៅ»។

លោក Paul Dauenhauer សាស្ត្រាចារ្យផ្នែកវិស្វកម្មគីមីនិងសម្ភារវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យ Minnesota និងអ្នកដឹកនាំការស្រាវជ្រាវ បាននិយាយថា «ក្រុមរបស់ពួកយើងបានបង្កើតដំណើរការបច្ចេកវិទ្យាគីមីថ្មីមួយដើម្បីធ្វើបង្គុំគីមី ឲ្យក្លាយជាម៉ូលេគុលសំខាន់ក្នុងសំបកកង់ឡាន ដែលបង្កើតចេញពីផលិតផលធម្មជាតិ ដូចជា ដើមឈើ, ស្មៅ, ឬពោត ជាដើម។ ការស្រាវជ្រាវនេះអាចនឹងមានឥទ្ធិពលយ៉ាងខ្លាំងលើឧស្សាហកម្មសំបកកង់យានយន្តរាប់សិបកោដិដុល្លារ»។

លោក Carol Bessel អគ្គនាយករងនាយកដ្ឋានមូលនិធិវិទ្យាសាស្ត្រជាតិ (NSF- National Science Foundation) ដែលបានផ្តល់មូលនិធិដល់មជ្ឈមណ្ឌលគីមីប៉ូលីមែរ (Center for Chemical Polymers) បាននិយាយថា «កិច្ចសហប្រតិបត្តិការគ្នាពិតជាមានសារៈសំខាន់ណាស់ ដើម្បីស្រាវជ្រាវយកជីវម៉ាស (Biomass) សម្រាប់វិធីសាស្ត្រអ៊ីសូប្រ៉ែន (Isoprene)។ កិច្ចសហប្រតិបត្តិការនិងការស្រាវជ្រាវរួម ដោយប្រើវិធីសាស្ត្រនិងជំនាញផ្សេងៗគ្នា គឺពិតជាវិធីដែលយើងខិតខំប្រឹងប្រែងដើម្បីជំរុញ ជាមួយនឹងមូលនិធិ NSF នេះ សម្រាប់កម្មវិធីច្នៃប្រឌិតផ្នែកគីមី (Program Innovation Chemical)»។

ថ្មីៗនេះ អ៊ីសូប្រ៉ែនត្រូវបានបង្កើតការបំលែងដោយយកម្ចៅក្លាយជាផ្នែកម៉ូលេគុលប្រេងកាត ដែលវាស្រដៀងនឹងដំណើរការណ៍របស់ប្រេងសាំង ដែលហៅថា «ការបំបែកជាតុ»។ អ៊ីសូប្រែនត្រូវបានបំបែកចេញជាផលិតផលរាប់រយហើយសុទ្ធ។ ក្នុងជំហានចុងក្រោយ អ៊ីសូប្រែនត្រូវបានប្រតិកម្មដោយខ្លួនឯងជាទម្រង់ច្រវ៉ាក់ដ៏វែង ដើម្បីបង្កើតជាប៉ូលីមែររឹង (Solid Polymers) ដែលជាសមាសធាតុដ៏សំខាន់សម្រាប់កង់ឡាន។

យោងតាមអ្នកស្រាវជ្រាវមួយចំនួនធំ, ជីវម៉ាស់ដែលកើតពីអ៊ីសូប្រែនបានក្លាយជាគំនិតនៃការបង្កើតដ៏សំខាន់សម្រាប់ក្រុមហ៊ុនកង់ឡានក្នុងទសវត្សកន្លងមកនេះ ដោយមានការខិតខំប្រឹងប្រែងយ៉ាងសកម្មដែលផ្តោតលើបច្ចេកវិទ្យាបំលែង (Fermentation Technology)។ យ៉ាងណាក៏ដោយ អ៊ីសូប្រែនដែលកកើតឡើងថ្មីបានបញ្ជាក់ពី ម៉ូលេគុលមួយៗខុសៗគ្នា ដើម្បីបង្កើតពីអតិសុខុមប្រាណ និងខំប្រឹងដើម្បីបង្កើតខ្លួនាពីដំណើរការជីវៈទាំងស្រុងឲ្យប្រកបដោយជោគជ័យ។

ដោយមានមូលនិធីផ្តល់ដោយ NSF, អ្នកស្រាវជ្រាវមួយ ចំនួនមកពីមជ្ឈមណ្ឌលគីមីប៉ូលីមែរបានផ្តោតលើដំណើរការថ្មីចាប់ផ្តើមជាមួយស្ករ ដែលបានមកពីជីវម៉ាស រួមមាន ស្មៅ ដើមឈើ និងពោត។ ពួកគេបានដឹងថា ដំណើរការជំហានទាំងបីមានភាពល្អប្រសើរនៅពេលវាបង្កាត់ពូជ «Hybridized» មានន័យថា វាបូកបញ្ចូលរវាងមេជីវសាស្ត្រដោយប្រើដោយអតិសុខុមប្រាណជាមួយនឹងប្រតិកម្មគីមីបន្សុទ្ធដែលវាប្រហែលទៅនឹងបច្ចេកទេសបន្សុទ្ធប្រេងកាត។

ជំហានដំបូងនៃដំណើរការថ្មីនេះគឺជាមេអតិសុខុមប្រាណរបស់ស្ករ ដូចជា គ្លុយកូសដែលបង្កើតបានពីជីវៈដំណាក់កាលកណ្តាល ហៅថា «អាស៊ីត Itaconic»។ ជំហានទី២, អាស៊ីត Itaconic នឹងមានប្រតិកម្មជាមួយអ៊ីដ្រូសែន (Hydrogen) ដើម្បីក្លាយជាសារធាតុគីមី ហៅថា មេទីល-THF (tetrahydrofuran)។ ជំហាននេះបានប្រសើរឡើងនៅពេលក្រុមស្រាវជ្រាវបានដឹងពីការបន្សំពីលោហៈនិងលោហៈតែមួយ (a unique metal-metal combination) ដែលបានបំពេញមុខងារជាកាតាលីករប្រកបដោយប្រសិទ្ធិភាពខ្ពស់។

របកគំហើញបច្ចេកទេសនៃដំណើរការកើតឡើងក្នុងជំហានទី៣ ដើម្បីដកយកទឹកពីមេទីល-THF ទៅជាអ៊ីសូប្រែន។ ថ្មីៗនេះ ការប្រើប្រាស់កាតាលីករមួយបានរកឃើញនៅសាកលវិទ្យាល័យ Minnesota ដែលហៅថា PSPP (Phosporouse Self-Pillared Pentasil) ដែលក្រុមនេះ អាចមានលទ្ធភាពបង្ហាញពីកាតាលីករដ៏មានប្រសិទ្ធីភាពខ្ពស់ប្រហែល ៩០% ភាគច្រើននៃផលិតផលបានពីការប្រើកាតាលីករបានក្លាយជាអ៊ីសូប្រែន។ ដោយការបញ្ចូលគ្នានូវជំហានទាំងបី ជាដំណើរមួយអ៊ីសូប្រ៉េនអាចជាប្រភពដែលរកឃើញវិញពីជីវៈម៉ាស។

លោក Frank Bates អ្នកជំនាញជំរុញការប្រើប្រាស់សារធាតុប្លាស្ទិកពិភពលោក និងជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រផ្នែកលោហៈនិងវិស្វករគីមីសាស្ត្រនៅសាកលវិទ្យាល័យ Minnesota បានឲ្យដឹងថា «ជីវៈមានប្រភពពីបង្គុំមានសក្តានុពលដើម្បីពង្រីកផលិតកម្មកង់ឡានក្នុងស្រុកប្រកបដោយភាពសន្សំសំចៃ ដោយប្រើប្រាស់នូវការរុករកថ្មីដែលអាចរកធនធានដ៏ងាយស្រួលមកជំនួសឥន្ធនៈហ្វូស៊ីល (Fossil Fuels)។ របកគំហើញនេះអាចមានផលប៉ះពាល់ដោយវិជ្ជមានផងដែរទៅលើបច្ចេកទេសដ៏ទៃច្រើនទៀត ដែលជំរុញឲ្យមានផលិតផលដែលផលិតចេញពីកៅស៊ូជាច្រើន (Rubber-based Products)»។



*គោលបំណងគឺកាត់បន្ថយនិង/ឬជំនួសឥន្ធនៈហ្វូស៊ីលដែលផ្អែកលើកៅស៊ូសំយោគក្នុងសំបកយានយន្ត*

# ទំព័រស្រាវជ្រាវ

## ចលនភាពរបស់សារធាតុគីមីដែលប្រើប្រាស់ក្នុងការកែច្នៃជ័រកៅស៊ូធម្មជាតិ

### ១.សេចក្តីផ្តើម

នៅក្នុងអត្ថបទនេះ លោកអ្នកនឹងទទួលបានចំណេះដឹង និងអត្ថប្រយោជន៍ជាច្រើន អំពីលក្ខណៈនៃដំណើរការកកដោយធម្មជាតិរបស់ទឹកជ័រ ការការពារមិនឲ្យកកដោយការប្រើប្រាស់អាម៉ូញ៉ាក់ និងការបង្កកដោយប្រើប្រាស់អាស៊ីតហ្វ័រមិច។ ក្រៅពីចំនុចសំខាន់ខាងលើនេះ យើងនឹងទទួលបានចំណេះដឹងបន្ថែមជាច្រើនទៀតដែលទាក់ទងទៅនឹងវិស័យកែច្នៃកៅស៊ូធម្មជាតិបន្ទាប់ពីការអានអត្ថបទនេះ។

ទឹកជ័រកៅស៊ូធម្មជាតិ (Latex) ដែលទទួលបានពីដើមកៅស៊ូ មានលក្ខណៈសខាប់ដូចទឹកដោះគោ ដែលមានរូបមន្តគីមី $C_5H_8$ ជាស្រលាយអ៊ីដ្រូកាបួរ ហើយមានសម្ព័ន្ធពីរជាន់ចំនួនពីរក្នុងមួយម៉ូលេគុលជ័រកៅស៊ូ។ វាមានឈ្មោះបច្ចេកទេសគឺ ឌីមេទីលប៊ុយតា-1,3-ឌៀន និងឈ្មោះអន្តរជាតិគឺ អ៊ីសូប្រ៉ែន (isoprene),




។ ធម្មជាតិរបស់ទឹកជ័រមានលក្ខណៈរាវ ដោយសារតែវាមានសម្ព័ន្ធពីរជាន់។ ទឹកជ័រនឹងកកបានដោយឯកឯងយ៉ាងសន្សឹមៗ ដោយមិនចាំបាច់ប្រើប្រាស់អាស៊ីត នេះក៏ព្រោះតែវាបានរងអុកស៊ីតកម្មពីបរិយាកាស។ សមាសធាតុផ្សំរបស់ជ័រកៅស៊ូធម្មជាតិមាន ទឹក(៦០%) អ៊ីដ្រូកាបួកៅស៊ូ (ជ័រស្ងួតសុទ្ធ, ៣០%-៣៥%) ប្រូតេអ៊ីន (១%-២%) លីពីត (១%-១,២%) គ្លុយស៊ីត (ស្ករ ១%) និងសារធាតុរ៉ែ ឬសារធាតុខនិច ( ១%)[១]។

### ២.ការកកដោយធម្មជាតិរបស់ទឹកជ័រ

#### ក. អំពើរបស់បាក់តេរីទៅលើទឹកជ័រ

នៅក្នុងទឹកជ័រផ្សំឡើងដោយស្ករដែលជាអាហារសម្រាប់រីកលូតលាស់របស់ពពួកបាក់តេរី។ ស្ករត្រូវបានបំលែងទៅជាអាស៊ីតហើយ ដូចជាអាស៊ីតអាសេទិច និងអាស៊ីតហ្វ័រមិច ដែលធ្វើឲ្យ pH របស់ទឹកជ័រថយចុះ និងនាំទៅដល់អស្ថេរភាពនៃគោលិកាកៅស៊ូក្នុងទឹក[១]។ បាក់តេរីក៏បានប្រើប្រាស់ស្ករសម្រាប់ផលិតថាមពលរួចបញ្ចេញអាស៊ីតឡាក់ទិចពីក្នុងខ្លួនរបស់ពួកវា[២]។



*រូបភាពពពួកបាក់តេរីដែលមាននៅក្នុងបរិយាកាស*

#### ខ.អ៊ីយ៉ុងម៉ាញ៉េស្យូម

អ៊ីយ៉ុងម៉ាញ៉េស្យូម (ឌីវ៉ាឡង់, $Mg^{2+}$) ក្នុងទឹកជ័រអាចមានប្រតិកម្មជាមួយនឹងអាស៊ីតខ្លាញ់នៃ

ស្រទាប់ស្រោបគោលិកាកៅស៊ូ ហើយបង្កើតជាសាប៊ូម៉ាញ៉េស្យូម។ ការធ្វើឲ្យទឹកជ័រញ៉េរគឺជាកត្តាមួយដែលជំរុញប្រតិកម្មប្រភេទនេះ[១]។

## ៣.ការថែរក្សាទឹកជ័រដោយអាម៉ូញ៉ាក់

អាម៉ូញ៉ាក់ជាឧស្ម័នដែលមានក្លិនឆ្អេះ ហើយវាឲ្យផលជាអាម៉ូញ៉ូមអ៊ីដ្រុកស៊ីត ($NH_4OH$) ស្ថិតនៅក្នុងទម្រង់ជាអ៊ីយ៉ុងនៅពេលលាយជាមួយទឹក។

**សមីការគីមីតាងប្រតិកម្ម៖**

$$NH_{3(g)} + H_2O_{(l)} \longleftrightarrow (NH_4^+ + OH^-)_{(aq)}$$

សមាសធាតុផ្សំរបស់អាម៉ូញ៉ាក់បានមកពីការផ្សំចូលគ្នារវាងឧស្ម័នអាសូត ($N_2$) (ជាឧស្ម័នពុលមិនទ្រទ្រង់ជីវិត ក្នុងភាពជាសូលុយស្យុង ឬជាឧស្ម័នត្រជាក់របស់វាអាចសំលាប់ជាលិការរបស់រាង្គកាយភាវៈរស់[៣]) និងឧស្ម័នអ៊ីដ្រូសែន ($H_2$)[៤]។

$$N_{2(g)} + 3H_{2(g)} \longrightarrow 2NH_{3(g)}$$

អាម៉ូញ៉ាក់ត្រូវបានគេប្រើប្រាស់សម្រាប់ការពារទឹកជ័រមិនឲ្យកកនៅឯចម្ការ មុនពេលយកទៅដល់កន្លែងកែច្នៃ។

- អាម៉ូញ៉ាក់អាចរារាំងពពួកបាក់តេរីមិនឲ្យធ្វើសកម្មភាពលើទឹកជ័រ។ ការប្រើប្រាស់អាម៉ូញ៉ាក់អាចរារាំងពពួកវាបានយ៉ាងមានប្រសិទ្ធិភាព ដោយសារតែក្លិនមិនល្អរបស់វា។
- អាម៉ូញ៉ាក់ គឺជាស្រទាប់ការពារអុកស៊ីតកម្មពីបរិយាកាស។ សារធាតុខនិចដែលមាននៅក្នុងទឹកជ័របានរងអុកស៊ីតកម្មពីបរិយាកាសក្លាយទៅជាកក (colloidal) និងបង្ករឲ្យមានពណ៌កើតមានឡើងនៅក្នុងទឹកជ័រដែលធ្វើឲ្យផ្ទៃជ័រក្រោយពេលកែច្នៃមានសភាពពណ៌មិនល្អ។ អាម៉ូញ៉ាក់មានតួនាទីក្នុងការចងសម្ព័ន្ធជាមួយអ៊ីយ៉ុងផូស្វាតនៅក្នុងទឹកជ័រដែលបានមកពីអ៊ីដ្រូលីសផូស្វ័រលីពីត ដើម្បីចាប់យកអ៊ីយ៉ុងលោហៈ (សារធាតុខនិច) ដែលមាននៅក្នុងទឹកជ័រមកចងផ្គុំជាទម្រង់កុំផ្លិច និងការពារវាមិនឲ្យមានឱកាសនឹងទទួរងអុកស៊ីតកម្មពីបរិយាកាសបាន[៥]។
- ការចាប់ម៉ាញ៉េស្យូមជាទម្រង់កុំផ្លិចដោយអាម៉ូញ៉ាក់ និងអ៊ីយ៉ុងផូស្វាត:
- $Mg^{2+}{}_{(aq)} + NH_{3(aq)} + HPO_4^{2-}{}_{(aq)} = MgNH_4PO_{4(aq)}$



*ទម្រង់កុំផ្លិចរបស់អ៊ីយ៉ុងផូស្វាតនិងអាម៉ូញ៉ាក់សហការគ្នាចាប់យកអ៊ីយ៉ុងលោហៈ*

ការប្រើប្រាស់អាម៉ូញ៉ាក់ត្រូវតែស្ថិតក្នុងមាត្រដ្ឋានដែលបានធ្វើការណែនាំ ដោយគេត្រូវប្រើសូលុយស្យុងអាម៉ូញ៉ាក់ក្នុងកំហាប់ ៥% ក្នុងបរិមាណ0,0៥% នៃអាម៉ូញ៉ាក់ធៀបនឹងទម្ងន់ទឹកជ័រ។ ការប្រើប្រាស់អាម៉ូញ៉ាក់លើសបរិមាណ អាចធ្វើឲ្យមានផលប៉ះពាល់នៅពេលធ្វើការបង្កកដោយប្រើអាស៊ីត ដោយសារតែ

pH របស់ទឹកជ័រខ្ពស់ជាង pH ធម្មតារបស់ទឹកជ័រធ្វើឲ្យការចំណាយបរិមាណអាស៊ីតច្រើននៅពេលបង្កក។

## កំណត់សំគាល់៖

- (aq): សូលុយស្យុងរាវ
- (s): អង្គធាតុរឹង ឬកករ
- (g): ឧស្ម័ន

## ឯកសារយោង


*(១)សាលាកប័ត្របច្ចេកទេស២០០៦/១ បច្ចេកទេសថែរក្សានិងបង្កកទឹកជ័រ បោះពុម្ពផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា*

(២)http://www.reference.com

(៣)https://semsportal.apachecorp.com/Public/Safety%20Alert%20Updates/nitrogen.pdf, *the dangers of Nitrogen ($N_2$)*

(៤)**https://pubchem.ncbi.nlm.nih.gov/compound/ammonia#section=Top**, *ammonia*

*(៥)manual for certification of Ammonia Preserved Concentrated Natural Rubber Latex ( IS 5430: 1981)*


*(មានតទៅលេខក្រោយ)*

# និន្នាការតម្លៃនិងស្ថិតិកៅស៊ូធម្មជាតិ

## តារាងទី១៖ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅតាមបណ្តាស្រុក ប្រចាំសប្តាហ៍ ខែកុម្ភៈ ឆ្នាំ២០១៧ (រៀល/គីឡូក្រាម)

| សប្តាហ៍ | ខេត្តកំពង់ចាម (ចំការលើ) | | ខេត្តត្បូងឃ្មុំ (មេមត់) | | ខេត្តត្បូងឃ្មុំ (អូររាំងឪ) | | ខេត្តកំពង់ធំ (ទំរីង) | | ខេត្តរតនគិរី (អូរជុំ) | |
|---|---|---|---|---|---|---|---|---|---|---|
| | ជ័រស្ងួត (DRC) | ជ័រកក (DRC 50%) | ជ័រស្ងួត (DRC) | ជ័រកក (DRC 50%) | ជ័រស្ងួត (DRC) | ជ័រកក (DRC 50%) | ជ័រស្ងួត (DRC) | ជ័រកក (DRC 50%) | ជ័រស្ងួត (DRC) | ជ័រកក (DRC 50%) |
| ១ | ៧០០០ | ៣៥០០ | ៦៧០០ | ៣២០០ | ៦៧០០ | ៣២០០ | ៧០០០ | ៣៤០០ | ៧១០០ | ៣៦០០ |
| ២ | ៧០០០ | ៣៥០០ | ៦៨០០ | ៣៣០០ | ៧០០០ | ៣៥០០ | ៧០០០ | ៣៤០០ | ៧១០០ | ៣៦០០ |
| ៣ | ៧០០០ | ៣៥០០ | ៧០០០ | ៣៥០០ | ៦៨០០ | ៣៣០០ | ៧០០០ | ៣៤០០ | ៧១០០ | ៣៦០០ |
| ៤ | ៧០០០ | ៣៥០០ | ៧០០០ | ៣៤០០ | ៦៨០០ | ៣៣០០ | ៧០០០ | ៣៤០០ | ៧១០០ | ៣៦០០ |

*ប្រភព៖*

- *អគ្គនាយកដ្ឋានកៅស៊ូ*
- *អត្រាប្តូរប្រាក់ធនាគារជាតិ 40៣៨រៀល/ដុល្លារ*

## តារាងទី២៖ តម្លៃកៅស៊ូនៅទីផ្សារប្រទេសថៃ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ (ឯកតា: បាត/គីឡូក្រាម)

| ថ្ងៃ | កៅស៊ូសម្ងួតឲ្យស្រពាប់ដោយខ្យល់ USS *1* | | | | | | | មធ្យម | សន្លឹកចំហុយ | ជ័រទាន | ទឹកជ័រនៅចម្ការ |
|---|---|---|---|---|---|---|---|---|---|---|---|
| | Hat Yai | Khlong Nga | Trang | Phuket | Surat thani | Rayong | Ubonrat chatani | | | | |
| 1 | 92,00 | 91,00 | 90,00 | 92,00 | 92,00 | 92,00 | 92,00 | 91,57 | 97,07 | 78,00 | 80,00 |
| 2 | 91,00 | 91,00 | 89,00 | 90,00 | 90,00 | 90,00 | 89,00 | 90,00 | 95,50 | 77,00 | 71,00 |
| 3 | 87,00 | 85,00 | 87,00 | 88,00 | 88,00 | 90,00 | 88,00 | 87,57 | 93,07 | 75,00 | 68,00 |
| 6 | 85,00 | 84,00 | 85,00 | 87,00 | 87,00 | 87,00 | 87,00 | 86,00 | 91,50 | 74,00 | 70,00 |
| 7 | 87,00 | 85,00 | 85,00 | 88,00 | 88,00 | 87,00 | 87,00 | 86,71 | 92,21 | 73,00 | 72.00 |
| 8 | 90,00 | 90,00 | 89,00 | 90,00 | 90,00 | 89,00 | 89,00 | 89,57 | 95,07 | 74,00 | 73.,00 |
| 9 | 90,00 | 90,00 | 89,00 | 90,00 | 90,00 | 89,00 | 89,00 | 89,57 | 95,07 | 74,00 | 73,00 |
| 10 | 90,00 | 89,00 | 90,00 | 90,00 | 90,00 | 89,00 | 90,00 | 89,71 | 95,21 | 74.00 | 72,00 |
| 14 | 93,00 | 92,00 | 93,00 | 93,00 | 93,00 | 93,00 | 93,00 | 92,86 | 98,35 | 75,00 | 73,00 |
| 15 | 92,00 | 92,00 | 91,00 | 92,00 | 92,00 | 92,00 | 92,00 | 91,86 | 97,35 | 75,00 | 75,00 |
| 16 | 90,00 | 89,00 | 90,00 | 91,00 | 91,00 | 90,00 | 90,00 | 90,14 | 95,64 | 75,00 | 80,00 |
| 17 | 88,00 | 88,00 | 88,00 | 89,00 | 89,00 | 88,00 | 89,00 | 88,43 | 93,92 | 73,00 | 80,00 |
| 20 | 85,00 | 84,00 | 85,00 | 85,00 | 85,00 | 85,00 | 85,00 | 84,86 | 90,35 | 70,00 | 72,00 |
| 21 | 85,00 | 85,00 | 83,00 | 85,00 | 85,00 | 85,00 | 85,00 | 84,71 | 90,21 | 70,00 | 73,00 |
| 22 | 83,00 | 83,00 | 82,00 | 83,00 | 83,00 | 83,00 | 83,00 | 82,86 | 88,35 | 68,00 | 71,00 |
| 23 | 81,00 | 81,00 | 79,00 | 80,00 | 80,00 | 82,00 | 81,00 | 80,57 | 86,07 | 67,00 | 70.00 |
| 24 | 75,00 | 75,00 | 73,00 | 75,00 | 75,00 | 76,00 | 75,00 | 74,86 | 80,35 | 63,00 | 68.,00 |
| 27 | 75,00 | 73,00 | 73,00 | 75,00 | 75,00 | 75,00 | 75,00 | 74,43 | 79,92 | 64,00 | 74,00 |
| 28 | 75,00 | 72,00 | 74,00 | 76,00 | 76,00 | 75,00 | 75,00 | 74,71 | 80,21 | 63,00 | 75,00 |

កំណត់សំគាល់៖ នេះជាថ្លៃកៅស៊ូក្នុងស្រុកនៃប្រទេសថៃបានមកពីសមាគមន៍កៅស៊ូថៃដែលបានអង្កេតយ៉ាងតិច២-៥សមាជិក/ថ្ងៃ

*1* USS = Unsmoked Sheets (កៅស៊ូសម្ងួតឲ្យស្រពាប់ដោយខ្យល់)

## តារាងទី៣៖ តម្លៃកៅស៊ូស្តង់ដាម៉ាឡេស៊ី SMR/FOB ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ (ដុល្លារ/តោន)

| កុម្ភៈ | SMR CV | SMR L | SMR 5 | SMR GP | SMR 10 | SMR 20 |
|---|---|---|---|---|---|---|
| 2 | 2 747,50 | 2 684,00 | 2 401,50 | 2 394,50 | 2 378,50 | 2 373,50 |
| 3 | 2 772,00 | 2 671,50 | 2 249,00 | 2 242,00 | 2 226,00 | 2 221,00 |
| 6 | 2 741,50 | 2 646,50 | 2 272,00 | 2 265,50 | 2 249,50 | 2 244,50 |
| 7 | 2 701,50 | 2 619,50 | 2 219,50 | 2 212,50 | 2 196,50 | 2 191,50 |
| 8 | 2 672,50 | 2 629,50 | 2 262,00 | 2 255,00 | 2 239,00 | 2 234,00 |
| 10 | 2 691,00 | 2 666,00 | 2 220,00 | 2 213,00 | 2 197,00 | 2 193,00 |
| 13 | 2 669,00 | 2 667,00 | 2 354,00 | 2 347,00 | 2 331,00 | 2 326,50 |
| 14 | 2 649,00 | 2 623,00 | 2 340,50 | 2 333,50 | 2 317,50 | 2 313,00 |
| 15 | 2 657,50 | 2 612,50 | 2 304,50 | 2 297,50 | 2 281,50 | 2 277,00 |
| 16 | 2 645,50 | 2 628,50 | 2 321,50 | 2 314,50 | 2 298,50 | 2 294,00 |
| 17 | 2 636,50 | 2 618,50 | 2 210,00 | 2 203,00 | 2 187,00 | 2 183,00 |
| 20 | 2 648,50 | 2 628,50 | 2 182,50 | 2 175,50 | 2 159,50 | 2 155,50 |
| 21 | 2 657,50 | 2 629,50 | 2 232,50 | 2 226,00 | 2 210,00 | 2 205,50 |
| 22 | 2 662,50 | 2 628,00 | 2 173,00 | 2 166,50 | 2 150,50 | 2 145,50 |
| 23 | 2 654,50 | 2 629,00 | 2 181,50 | 2 174,50 | 2 158,50 | 2 154,00 |
| 24 | 2 616,00 | 2 605,50 | 2 086,50 | 2 079,50 | 2 063,50 | 2 059,50 |
| 27 | 2 602,00 | 2 579,50 | 2 149,00 | 2 142,00 | 2 126,00 | 2 121,00 |
| 28 | 2601,50 | 2 572,00 | 2 068,00 | 2 061,00 | 2 045,00 | 2 040,50 |
| មធ្យម | 2 668,10 | 2 0629,90 | 2 234,90 | 2 227,90 | 2 211,90 | 2 207,40 |
| អតិបរមា | 2 772,00 | 2 684,00 | 2 401,50 | 2 394,50 | 2 378,50 | 2 373,50 |
| អប្បបរមា | 2 601,50 | 2 572,00 | 2 068,00 | 2 061,00 | 2 045,00 | 2 040,50 |




តម្លៃកៅស៊ូស្តង់ដាម៉ាឡេស៊ីលេខ១០ (SMR 10) បានធ្លាក់បន្តិចនៅត្រឹម ២៣៩៤,៥០ដុល្លារ/តោន ក្នុងខែកុម្ភៈ ឆ្នាំ២០១៧នេះ បើធៀបទៅនឹងខែមករា ឆ្នាំ២០១៧ ដែលមានតម្លៃ ២៤៣៣ដុល្លារ/តោន ដូចនេះសន្ទស្សន៍តម្លៃថយចុះ ១,០០២២ មានន័យថាតម្លៃកៅស៊ូខែកុម្ភៈ ឆ្នាំ២០១៧ បានថយចុះ ២,២៤%។

SMR = Standard Malaysian Rubber (កៅស៊ូស្តង់ដាម៉ាឡេស៊ី), FOB = Free-on-Board (ថ្លៃទំនិញដឹកដល់កប៉ាល់)

## តារាងទី៤៖ តម្លៃកៅស៊ូធម្មជាតិចេញដោយ Association of Natural Rubber Producing Countries ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ (ដុល្លារ/តោន)

| កុម្ភៈ | Latex 60% | RSS | | TSR | |
|---|---|---|---|---|---|
| | ម៉ាឡេស៊ី[៤] | បាងកក RSS 3[២] | កូតាយ៉ាម RSS 4[៣] | បាងកក TSR 20[២] | កូឡាឡាំពួរ SMR 20[១] |
| 1 | - | 2 874,10 | 2 365,50 | 2 535,40 | - |
| 2 | 1 869,70 | 2 849,70 | 2 372,00 | 2 510,50 | 2 373,50 |
| 3 | 1 862,30 | 2 812,40 | 2 359,50 | 2 481,90 | 2 221,00 |
| 6 | 1 836,10 | 2 811,90 | 2 359,00 | 2 429,30 | 2 244,50 |
| 7 | 1 811,30 | - | 2 360,00 | - | 2 191,50 |
| 8 | 1 818,20 | - | 2 377,00 | - | 2 234,00 |
| 9 | - | - | 2  387,50 | - | - |
| 10 | 1 814,20 | - | 2 390,50 | - | 2 193,00 |
| 13 | 1 814,60 | - | 2 396,50 | - | 2 326,50 |
| 14 | 1 814,90 | - | 2 405,00 | - | 2 313,00 |
| 15 | 1 823,60 | - | 2 413,50 | - | 2 277,00 |
| 16 | 1 837,80 | - | 2 412,50 | - | 2 294,00 |
| 17 | 1 835,90 | - | 2 394,00 | - | 2 183,00 |
| 20 | 1 836,70 | - | 2 389,00 | - | 2 155,50 |
| 21 | 1 848,30 | - | 2 389,00 | - | 2 205,50 |
| 22 | 1 845,30 | -- | 2 389,50 | - | 2 145,50 |
| 23 | 1 824,40 | - | 2 371,50 | - | 2 154,00 |
| 24 | 1 775,,40 | - | 2 364,00 | - | 2 059,50 |
| 27 | 1 764,80 | - | 2 353,00 | - | 2 121,00 |
| 28 | 1 771,80 | - | 2 322,50 | - | 2 040,50 |

**សំគាល់៖**

(១) ថ្លៃរូបវន្តផ្ទុកលើនាវាកំណត់ដោយអ្នកទិញនៅល្ងាចម៉ោង ៥:00
(២) ថ្លៃរូបវន្តផ្ទុកលើនាវាកំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូថៃ
(៣) ថ្លៃជាមធ្យមកំណត់ដោយទីផ្សារតណ្ឌា (ដែលទាក់ទងនឹងថ្លៃទីផ្សារក្នុងស្រុក និងមិនគិតថ្លៃពន្ធ ឬថ្លៃផ្សេង)
(៤) ថ្លៃកំណត់ដោយអ្នកទិញដែលបានរាយការណ៍ជាផ្លូវការ ដោយក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី

**ពាក្យកាត់៖**

*1* TSR = Technical Specified Rubber (កៅស៊ូបញ្ជាក់គុណភាពតាមបច្ចេកទេស)
*2* RSS = Ribbed Smoked Sheets (កៅស៊ូសន្លឹកសម្ងួតដោយកំដៅនិងផ្សែង)
*3* Latex 60% (ទឹកជ័រខាប់៦០%)
*4* SMR = Standard Malaysia Rubber (កៅស៊ូស្តង់ដាប្រទេសម៉ាឡេស៊ី)
*5* STR = Standard Thai Rubber (កៅស៊ូស្តង់ដាប្រទេសថៃ)

# និន្នាការតម្លៃកៅស៊ូនិងទស្សនៈខ្លីៗ

តម្លៃកៅស៊ូនៅលើទីផ្សារសំខាន់ៗកំពុងមានភាពប្រសើរឡើងនៅកំឡុងពេល ២ខែដើមឆ្នាំនេះ។ ចំពោះទីផ្សារកៅស៊ូដុំ (Block Rubber) តម្លៃកៅស៊ូប្រភេទ SMR-20 មានកំណើន ១៣,៨% នៅកូឡាឡាំពួរ និងកៅស៊ូប្រភេទ TSR-20 មានកំណើន ១០,៧% នៅបាងកក ក្នុងកំឡុងខែកុម្ភៈនេះ បើប្រៀបធៀបទៅនឹងខែមុន។ យ៉ាងណាក៏ដោយ តម្លៃក៏បានប្រសើរឡើងចំពោះកៅស៊ូទីផ្សារកៅស៊ូសន្លឹក RSS-3 នៅបាងកក (៩,៧%) និងកៅស៊ូសន្លឹក RSS-4 នៅកូត្តូយ៉ាម ប្រទេសឥណ្ឌា (១០,៧%)។ តម្លៃនេះត្រូវបានគាំទ្រដោយកត្តាផ្គត់ផ្គង់មានតុល្យភាពគ្នា ពីព្រោះវាជារដូវកាលសម្រាកចៀរ។ រដូវកាលនៃធ្លាក់ចុះការផ្គត់ផ្គង់ត្រូវបានបញ្ចប់ និងផលិតផលបានធ្លាក់ចុះ បណ្តាលមកពីទឹកជំនន់នៅភាគខាងត្បូងប្រទេសថៃដែលកំពុងកើតឡើង រហូតដល់ពាក់កណ្តាលខែមករា។

### តារាងទី៥៖ តម្លៃកៅស៊ូធម្មជាតិប្រចាំខែជាមធ្យមលើទីផ្សារសំខាន់ៗ

(ដុល្លារ/តោន)

| **ទីផ្សារ & ប្រភេទ** | មករា ២០១៧ | កុម្ភៈ ២០១៧ | % ប្រែប្រួល |
|---|---|---|---|
| **SMR 20 (កូឡាឡាំពួរ)** | 2 180 | 2 210 | 13,8 |
| **STR 20 (បាងកក)** | 2 250 | 2 490 | 10,7 |
| **RSS 3 (បាងកក)** | 2 590 | 2 840 | 9,7 |
| **RSS 4 (កូតាយ៉ាម)** | 2 150 | 2 380 | 10,7 |

### តារាងទី៦៖ ការនាំចេញកៅស៊ូធម្មជាតិ
### របស់ប្រទេសជាសមាជិកសមាគម ANRPC (000តោន)

| **ប្រទេស** | **២០១៦** (ពេញ១ឆ្នាំ) | **មករា-កុម្ភៈ ២០១៦** | **មករា-កុម្ភៈ ២០១៧** | % **២០១៧** |
|---|---|---|---|---|
| ថៃ | 3 600 | 632 | 628 | -0,6 |
| ឥណ្ឌូនេស៊ី | 2 528 | 397 | 413 | 4,1 |
| វៀតណាម | 1 254 | 146 | 144 | -1,4 |
| ម៉ាឡេស៊ី | 1 053 | 161 | 173 | 7,8 |
| កម្ពុជា | 145 | 18 | 27 | 54,9 |
| ប្រទេសដទៃទៀត | 202 | 29 | 37 | 29,1 |
| **ANRPC** | **8 782** | **1 381** | **1 422** | **3,0** |

## ក្រាហ្វិកទី១៖ តម្លៃកៅស៊ូនៃប្រភេទ SMR 20 ធៀបនឹងតម្លៃប្រេងឆៅរបស់ក្រុមហ៊ុន Brent (១ ធ្នូ ២០១៦ - ២១ កុម្ភៈ ២០១៧)




ក្នុងកំឡុងខែកុម្ភៈ ឆ្នាំ២០១៧នេះ តម្លៃប្រេងស្ថិតនៅនឹងថ្កល់គឺ ៥៤ដុល្លារ/បារ៉ែល។ តម្លៃកៅស៊ូ SMR-20 បានងើបឡើងវិញបន្តិច បន្ទាប់ពីការធ្លាក់ចុះយ៉ាងកំហុកកាលពីដើមខែ។ ការធ្លាក់ចុះកៅស៊ូ SMR-20 នៅដើមខែកុម្ភៈ ត្រូវបានគេដឹងថា ជាការធ្លាក់ចុះដោយស្វ័យប្រវត្តិក្នុងទីផ្សារតាមរយៈការធ្វើពាណិជ្ជកម្ម មានតែមួយគត់លើទីផ្សារតូក្យូ (TOCOM) នៅពេលដែលទីផ្សារហ៊ុនសៀងហៃនៅបន្តបិទសម្រាប់ថ្ងៃសម្រាកបុណ្យចូលឆ្នាំចិន។ ក្នុងកំឡុងបុណ្យចូលឆ្នាំចិននេះ ទីផ្សារកៅស៊ូ TOCOM មានតម្លៃកើនឡើង ៦% ក្នុងរយៈពេល ៣ថ្ងៃ គឺ ៣៥១,៩យ៉េន/គីឡូក្រាម នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧។ តម្លៃកៅស៊ូ SMR-20 មាននិន្នាការប្រែប្រួលតិចតួចក្នុងទីផ្សារប្រេងឆៅ វាមានឥទ្ធិពលតិចតួចបំផុត។

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែកុម្ភៈ ២០១៧*

## ក្រាហ្វិកទី២៖ និន្នាការតម្លៃកៅស៊ូនៅពេលអនាគត RSS 3 នៅទីផ្សារ TOCOM និង ប្រាក់យ៉េនប្រទេសជប៉ុន




បើប្រៀបធៀបទៅនឹងខែមករា ឆ្នាំ២០១៧ តម្លៃឥទ្ធិពលនៃប្រាក់យ៉េនជប៉ុនក្នុងទីផ្សារតូក្យូមានទំនាក់ទំនងយ៉ាងខ្លាំង (ដ្យាក្រាមខាងលើ) ខណៈពេលដែល ភាពរឹងមាំនៃប្រាក់យ៉េនធៀបនឹងដុល្លារសហរដ្ឋអាមេរិកនៅដើមខែនេះ។ តម្លៃកៅស៊ូនាពេលអនាគតនៅទីផ្សារ TOCOM បានធ្លាក់ចុះត្រឹម ២៩៨,៩យ៉េន/គីឡូក្រាម នៅថ្ងៃទី០៦ កុម្ភៈ ២០១៧។ ជាលទ្ធផល ការធ្លាក់ចុះតម្លៃប្រាក់យ៉េននៅពាក់កណ្ដាលខែកុម្ភៈ, តម្លៃកៅស៊ូនាពេលអនាគតនៅទីផ្សារ TOCOM បានកើនឡើងត្រលប់មកវិញ ៣២៦,៤យ៉េន/គីឡូក្រាម នៅថ្ងៃទី១៧ កុម្ភៈ ឆ្នាំ២០១៧។ យ៉ាងណាក៏ដោយ តម្លៃកៅស៊ូនាពេលអនាគតនៅទីផ្សារ TOCOM ក៏បានបាត់បង់របស់វាដោយកម្លាំងចលករ នៅពេលប្រាក់យ៉េនបានពង្រឹងនៃការកើនថ្លៃនៅចុងខែ ហើយនេះជាកំណត់ត្រានៃចំណុចធ្លាក់ចុះអប្បបរមាកំឡុងខែនេះ ក្នុងតម្លៃ ២៦៩,៤យ៉េន/គីឡូក្រាម នៅថ្ងៃទី២៣ កុម្ភៈ ឆ្នាំ២០១៧។

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែកុម្ភៈ ២០១៧*

# តារាងទី៧៖ តម្លៃកៅស៊ូសន្លឹកលេខ៣ ( RSS3 ) នៅលើទីផ្សារហ៊ីន TOCOM ( យ៉េន/គីឡូក្រាម )

| កាលបរិច្ឆេទនៃការធ្វើពាណិជ្ជកម្ម | កិច្ចសន្យាប្រចាំខែ | | | | | |
|---|---|---|---|---|---|---|
| | កុម្ភៈ ១៧ | មីនា ១៧ | មេសា១៧ | ឧសភា ១៧ | មិថុនា ១៧ | កក្កដា ១៧ |
| ១ កុម្ភៈ | 334.0 | 328,0 | 322,5 | 319,4 | 313,6 | 315,5 |
| ៦ កុម្ភៈ | 320,3 | 313,3 | 306,0 | 303,4 | 299,6 | 298,9 |
| ៧ កុម្ភៈ | 322,9 | 317,9 | 310,3 | 306,9 | 303,7 | 303,5 |
| ៨ កុម្ភៈ | 329,9 | 325,4 | 320,0 | 313,2 | 312,0 | 309,0 |
| ៩ កុម្ភៈ | 331,4 | 327,4 | 319,5 | 314,6 | 310,5 | 307,7 |
| ១០ កុម្ភៈ | 337,8 | 334,0 | 323,5 | 319,5 | 315,0 | 311,7 |
| ១៣ កុម្ភៈ | 352,5 | 349,4 | 339,2 | 335,5 | 328,5 | 326,0 |
| ១៤ កុម្ភៈ | 349,5 | 349,0 | 340,1 | 336,1 | 330,0 | 326,4 |
| ១៥ កុម្ភៈ | 347,0 | 346,8 | 338,9 | 333,3 | 324,0 | 319,7 |
| ១៦ កុម្ភៈ | 347,1 | 345,5 | 336,5 | 332,7 | 320,2 | 316,2 |
| ១៧ កុម្ភៈ | 330,1 | 325,5 | 316,5 | 312,7 | 300,9 | 296,2 |
| ២០ កុម្ភៈ | 326,1 | 320,1 | 313,1 | 308,2 | 299,8 | 295,0 |
| ២១ កុម្ភៈ | 331,0 | 319,4 | 311,4 | 305,6 | 298,3 | 292,0 |
| ២២ កុម្ភៈ | 331,0 | 315,6 | 308,3 | 303,4 | 295,2 | 295,2 |
| ២៣ កុម្ភៈ | 302,6 | 289,7 | 283,3 | 275,2 | 269,7 | 269,4 |
| ២៤ កុម្ភៈ | 302,1 | 289,3 | 283,9 | 275,5 | 269,6 | 267,1 |

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែកុម្ភៈ ២០១៧*

*អត្រា៖ ១ យ៉េន = ០,០០៨៨៩ដុល្លារ*

## តារាងទី៩៖ តម្លៃកៅស៊ូសន្លឹកលេខ៣ ( RSS3 ) នៅលើទីផ្សារហ៊ុនសៀងហៃ ( យ័ន/តោន )

| កាលបរិច្ឆេទនៃការធ្វើពាណិជ្ជកម្ម | កិច្ចសន្យាប្រចាំខែ | | | | | |
|---|---|---|---|---|---|---|
| | មីនា ១៧ | មេសា១៧ | ឧសភា ១៧ | មិថុនា ១៧ | កក្កដា ១៧ | សីហា ១៧ |
| ១ កុម្ភៈ | 20 880 | 21 230 | 21 475 | 21 445 | 21 440 | 21 500 |
| ៣ កុម្ភៈ | 19 870 | 20 270 | 20 175 | 20 200 | 20 120 | 21 090 |
| ៦ កុម្ភៈ | 19 715 | 20 135 | 20 080 | 20 115 | 20 260 | 20 235 |
| ៧ កុម្ភៈ | 20 370 | 20 365 | 20 680 | 20 555 | 20 425 | 20 595 |
| ៨ កុម្ភៈ | 20 640 | 20 410 | 20 725 | 20 770 | 20 730 | 20 625 |
| ៩ កុម្ភៈ | 20 410 | 20 480 | 20 585 | 20 680 | 20 700 | 20 625 |
| ១០ កុម្ភៈ | 20 970 | 20 880 | 20 970 | 21 175 | 20 830 | 20 970 |
| ១៣ កុម្ភៈ | 21 730 | 21 680 | 22 005 | 22 095 | 21 225 | 21 910 |
| ១៤ កុម្ភៈ | 21 705 | 21 830 | 22 015 | 22 065 | 22 180 | 21 995 |
| ១៥ កុម្ភៈ | 21 210 | 21 700 | 21 550 | 21 690 | 21 885 | 21 960 |
| ១៦ កុម្ភៈ | 21 400 | 21 530 | 20 320 | 20 450 | 20 465 | 20 990 |
| ១៧ កុម្ភៈ | 19 820 | 20 120 | 20 380 | 20 365 | 20 350 | 20 615 |
| ២០ កុម្ភៈ | 20 060 | 20 075 | 20 300 | 20 320 | 19 945 | 20 615 |
| ២១ កុម្ភៈ | 19 815 | 19 950 | 20 090 | 20 130 | 20 200 | 20 365 |
| ២២ កុម្ភៈ | 19 580 | 19 975 | 20 040 | 20 160 | 20 180 | 20 350 |
| ២៣ កុម្ភៈ | 18 615 | 18 635 | 18 690 | 18 750 | 18 765 | 19 120 |
| ២៤ កុម្ភៈ | 18 420 | 18 580 | 18 800 | 18 760 | 18 760 | 18 995 |

*ប្រភព៖ ព្រឹត្តិបត្រ ANRPC ប្រចាំខែកុម្ភៈ ២០១៧*

*អត្រា៖ ១ យ័ន = ០,១៤៤ដុល្លារ*

# ចំណេះដឹងទូទៅ

## ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ

## ( IRRDB-International Rubber Reseach and Development Board )

*ប្រភពពី៖ www.anrpc.org*
*ប្រែសម្រួលដោយ លោក យុន កក្កដា,*
*អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ*

### ១- ប្រវត្តិនៃការកកើត

**ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ** ដែលហៅជាភាសាអង់គ្លេសថា " **IRRDB" (The International Rubber Research and Development board)** គឺជាបណ្តាញស្រាវជ្រាវ និងអភិវឌ្ឍ ដែលប្រមូលផ្តុំចងក្រងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិពីគ្រប់បណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ និងបានក្តោបក្តាប់ផលិតផលកៅស៊ូធម្មជាតិ ប្រមាណ៩៥% នៃពិភពលោក។

គោលគំនិតដំបូងនៃការបង្កើតក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ " IRRDB " បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៣០។ នៅក្នុងអំឡុងពេលនោះ គណៈកម្មាធិការមួយមានឈ្មោះថា " **គណៈកម្មាធិការនិយតកម្មកៅស៊ូអន្តរជាតិ** (**The International Rubber Regulation Committee**)" ត្រូវបានបង្កើតឡើងដើម្បីការពារអ្នកដាំកៅស៊ូពីឥទ្ធិពលនៃការធ្លាក់ចុះតម្លៃកៅស៊ូយ៉ាងធ្ងន់ធ្ងរ នៅពាក់កណ្តាលទសវត្សឆ្នាំ១៩៣០។ គណៈកម្មាធិការនេះមានគោលបំណងដាក់កម្រិតលើបរិមាណផលិតផលនិងបរិមាណនាំចេញ ដើម្បីកែសម្រួលបរិមាណផ្គត់ផ្គង់ឲ្យឆ្លើយតបទៅនឹងបរិមាណនៃតម្រូវការជាក់ស្តែង។ ទន្ទឹមគ្នានេះ គណៈកម្មាធិការក៏បានទទួលស្គាល់ផងដែរអំពីសារៈសំខាន់នៃការជំរុញលើកទឹកចិត្តឲ្យមានការស្រាវជ្រាវនិងអភិវឌ្ឍដែលមានគោលដៅត្រឹមត្រូវនិងច្បាស់លាស់។

នៅក្នុងឆ្នាំ១៩៣៧ គណៈកម្មាធិការនេះបានបង្កើត "**ក្រុមប្រឹក្សាស្រាវជ្រាវកៅស៊ូអន្តរជាតិ** (**International Rubber Research Board**)" ដើម្បីសម្របសម្រួលការងាររបស់**វិទ្យាស្ថានជាតិ** (**National Institutes**) នានាជាមួយនឹង**គណៈកម្មាធិការអភិវឌ្ឍកៅស៊ូអន្តរជាតិ** (**International Rubber Development Committee**) ក្នុងគោលបំណងឲ្យទទួលរ៉ាប់រងអភិវឌ្ឍពាណិជ្ជកម្មនូវរាល់របកគំហើញទាំងឡាយដែលទទួលបានពីការស្រាវជ្រាវ។ ហេតុមកដល់ឆ្នាំ១៩៦០ ស្ថាប័នទាំងពីរនេះបានច្របាច់បញ្ចូលគ្នាបង្កើតបានជាក្រុមប្រឹក្សា "IRRDB" ហេតុមក។

បច្ចុប្បន្ន ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍកៅស៊ូអន្តរជាតិ "IRRDB" បាននឹងកំពុងធ្វើសកម្មភាពគ្របដណ្តប់លើគ្រប់ទិដ្ឋភាពស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូធម្មជាតិ ចាប់តាំងពីការដាំដុះរហូតដល់ការអភិវឌ្ឍជាផលិតផលថ្មីៗ។

## ២- សមាជិកភាព

រហូតមកដល់បច្ចុប្បន្ន ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍកៅស៊ូអន្តរជាតិ "IRRDB" មានមជ្ឈមណ្ឌលស្ថាប័ន ឬវិទ្យាស្ថានស្រាវជ្រាវចំនួន១៩ប្រទេសជាសមាជិក។ **វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា " វសកក "** **(Cambodia Rubber Research Institute "CRRI")** បានចូលជាសមាជិកទី១៦ នៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍកៅស៊ូអន្តរជាតិ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ IRRDB ដែលប្រព្រឹត្តិធ្វើឡើងនៅក្នុងក្រុង**ម៉ុងប៉ីលីយេ** ប្រទេសបារាំង កាលពីថ្ងៃទី ២៧ - ២៨ ខែកញ្ញា ឆ្នាំ២០០១។

កាលពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦កន្លងទៅ **វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា** បានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទកៅស៊ូអន្តរជាតិឆ្នាំ២០១៦ ក្រោមប្រធានបទ **"ចីរភាពនៃឧស្សាហកម្មកៅស៊ូធម្មជាតិ៖ បញ្ហា ការប្រឈម និងកាលានុវត្តភាព"** រួមទាំងកិច្ចប្រជុំប្រចាំឆ្នាំ២០១៦ របស់ IRRDB នៅខេត្តសៀមរាប។




ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និសីទកៅស៊ូអន្តរជាតិឆ្នាំ២០១៦

## ប្រទេស និងស្ថាប័នស្រាវជ្រាវជាសមាជិក IRRDB

| លេខរៀង | ប្រទេស | ស្ថាប័នស្រាវជ្រាវជាសមាជិក IRRDB |
|---|---|---|
| ១ | ប្រេស៊ីល | សមាគមអ្នកដាំកៅស៊ូ និងកម្មន្តសាលករ (APABOR) |
| ២ | កាម៉េរូន | វិទ្យាស្ថានស្រាវជ្រាវក្សេត្រសាស្ត្រ (NRRP) |
| ៣ | ចិន | បណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិចប្រទេសចិន (CATAS) |
| ៤ | វៀតណាម | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូវៀតណាម (RRIV) |
| ៥ | កូតឌីវ័រ | មជ្ឈមណ្ឌលជាតិស្រាវជ្រាវក្សេត្រសាស្ត្រ (CNRA) |
| ៦ | បារាំង | មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវក្សេត្រសាស្ត្រ សម្រាប់អភិវឌ្ឍន៍ (CIRAD) |
| ៧ | ហ្គាបុង | មជ្ឈមណ្ឌលជំនួយបច្ចេកទេសកៅស៊ូ (CATH) |
| ៨ | ឥណ្ឌា | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូឥណ្ឌា(RRII) |
| ៩ | ឥណ្ឌូណេស៊ី | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូឥណ្ឌូណេស៊ី(IRRI) |
| ១០ | ម៉ាឡេស៊ី | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូម៉ាឡេស៊ី(RRIM) |
| ១១ | ម៉ិចស៊ិក | វិទ្យាស្ថានជាតិស្រាវជ្រាវព្រៃឈើ កសិកម្ម និងផលិតកម្មសត្វ |
| ១២ | ហ្វីលីពីន | (INIFAP) |
| ១៣ | ស្រីលង្កា | មជ្ឈមណ្ឌលស្រាវជ្រាវកៅស៊ូហ្វីលីពីន(PHILRUBBER) |
| ១៤ | ថៃ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូស្រីលង្កា (RRISL) |
| ១៥ | នីហ្សេរីយ៉ា | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូថៃ(RRIT) |
| ១៦ | កម្ពុជា | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូនីហ្សេរីយ៉ា(RRIN) |
| ១៧ | អេត្យូពី | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (CRRI) |
| ១៨ | ហ្គាតេម៉ាឡា | វិទ្យាស្ថានស្រាវជ្រាវអេត្យូពី |
| ១៩ | ភូមា | វិទ្យាស្ថានស្រាវជ្រាវហ្គាតេម៉ាឡា |
| | | វិទ្យាស្ថានស្រាវជ្រាវភូមា |

(មានតនៅលេខក្រោយ)